# ជំពូកទី១ សេចក្ដីផ្ដើម

## ១.១. មូលហេតុ

ការសិក្សាស្វែងយល់ប្រវត្តិសាស្ត្រឲ្យបានច្រើន គឺជាអំពើដ៏ល្អមួយសម្រាប់យល់ដឹងពីប្រវត្តិសាស្ត្រនៅក្នុងប្រទេសជាតិរបស់ខ្លួនឲ្យបានយល់ច្បាស់អំពីព្រឹត្តិការណ៍កើតឡើងពិតប្រាកដ ។កុំឲ្យសូម្បីតែប្រវត្តិសាស្ត្ររបស់ខ្លួនមិនស្គាល់ផង ធ្វើយ៉ាងម្ដេចអាចបង្ហាញសកលលោកឲ្យបានដឹងពីវប្បធម៌ អរិយធម៌ និងបញ្ហាដែលបានកើតមានឡើងនៅក្នុងសង្គមជាតិ ។ ជាកត្តាសំខាន់មួយផងដែរ ដែលកូនខ្មែរគ្រប់ជំនាន់ក្រោយបានសិក្សាស្វែងយល់ ពីចំណុចខុសគ្នារវាងរបបមួយនិង ឈានទៅរករបបមួយផ្សេងទៀតនៅក្នុងប្រវត្តិសាស្ត្រ ។

ការសិក្សាស្វែងយល់ពីសម័យកាលប្រវត្តិសាស្ត្រនីមួយៗ អាចធ្វើឲ្យយើងដឹងពីរបបនៃការគ្រប់គ្រងនិងជីវភាពរស់នៅរបស់ប្រជាជន ការចិញ្ចឹមជិវិត និងការកសាងប្រទេស ។ នៅក្នុងការគ្រប់គ្រងរបបនីមួយៗតែងតែមានភាពខុសគ្នាជាក់ជាមិនខាន គឺអាចទៅតាមស្ថានភាពរបស់អ្នកដឹកនាំនៅក្នុងប្រទេសនោះ ព្រោះថាបើនៅក្នុងរបបមួយដែលមានអ្នកដឹកនាំប្រកបដោយឧត្តមភាព សច្ចៈភាព ភាពត្រឹមត្រូវប្រកបដោយសីលធម៌ ទសពិតរាជធម៌នោះ ប្រទេសជាតិ ប្រជាជននិងរស់នៅបានសេចក្ដីសុខសាន្ត រុងរឿងប្រទេសជាតិមានភាពរីកចម្រើន ទៅតាមអ្វីដែលអ្នកគ្រប់គ្រងបានប្រតិបត្តិ ។ តែបើអ្នកដឹកនាំគ្មានសច្ចៈភាព វាពិតជាធ្វើឲ្យប្រទេសជាតិគ្មានការីកចម្រើន គ្មានសន្តិភាព គ្មានភាពស្ងៀមស្ងាត់ និងមានតែការបង្ហូរឈាមគ្នាទៅវិញទៅមក។

បើយើងសង្កេត ទៅលើរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាវិញយើងនិងឃើញថា គឺមានការតស៊ូទៅមុខជារៀងរហូត ដោយមានការចូលរួមពីរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលបានបង្កើតឡើងនៅថ្ងៃទី២ ធ្នូ ១៨៧៨និងកងទ័ពវៀតណាមដែលជួយពីក្រោយ។ទីបំផុតក្រោមគោលយោបាយវិសុទ្ធកម្មរបស់ពួក ប៉ុល ពត ត្រូវបានសម្លាប់យ៉ាងរង្គាលទៅលើជួរអ្នកតស៊ូបដិវត្តន៍ ។

## ១.២ គោលបំណង

ក្នុងការរៀបរៀងសៀវភៅនេះឡើង យើងខ្ញុំពិតជាចង់ឲ្យសៀវភៅនេះកាន់តែមានភាពទូលំទូលាយ និងបន្ថែមនូវពុទ្ធិមួយទៀតដ៏សំខាន់សម្រាប់មិត្តអ្នកសិក្សាស្រាវជ្រាវពីប្រវត្តិសាស្ត្រកម្ពុជា ។ ព្រោះនៅរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានេះយើងនិងអាចយល់ដឹងពីការគ្រប់គ្រង និងដឹកនាំប្រទេសដោយយុទ្ធសាស្ត្របែបណា ទើបអាចរំដោះប្រទេសជាតិឲ្យរួចផុតពី

របបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យដែលបានបង្ហូរឈាមប្រជាជននិងអ្នកស្នេហាជាតិអស់យ៉ាងច្រើន ។តែក៏ចង់ឲប្រជាជនទាំងអស់យល់ដឹងអំពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាផងដែល។តើមានការរីកចំរើននិងមានការអន់ថយយ៉ាងដូចម្តេចខ្លះ?

## ១.៣ គោលដៅ

*១-ការលេចឡើងនូវសាប័នអំណាចរដ្ឋ នៅក្នុងប្រទេសដែលត្រូវបង្កើតឡើង ពិសេសក្នុងដំណាក់កាលឆ្នាំ១៩៧៩- ១៩៨១។*

*២-នៅពេលដែល បង្កើតឡើងនូវរចនាសម្ព័ន្ធបក្សជាអង្គការដឹកនាំទាំងស្រុង។*

ចង់បង្ហាញដល់សិស្សានុសិស្សឲ្យយល់ដឹងអំពីការគ្រប់គ្រង់ប្រទេសនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ឲ្យបានច្បាស់លាស់ដើម្បីផលប្រយោជន៍ដល់សិស្សានុសិស្សសម្រាប់ធ្វើការស្រាវជ្រាវអំពីប្រវត្តិសាស្ត្រកម្ពុជា ។ ម្យ៉ាងទៀតសៀវភៅនេះគឺជាសម្បទានដ៏ល្អមួយដែរ ដើម្បីស្វែងរកភាពសុក្រឹត្យនៃប្រវត្តិសាស្ត្រកម្ពុជានៅក្នុងសម័យកាលមួយ ។ វាក៏អាចជួយឲ្យយើងស្វែងយល់អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រក្នុងដំណាក់កាលនេះផងដែរ ។

## ១.៤ ចំណោទបញ្ហា

ជាការពិតណាស់នៅក្នុងរបបគ្រប់គ្រងនីមួយៗតែងតែផ្តល់គុណវិបត្តិនិង គុណសម្បត្តិដល់សង្គមដោយគ្មានរបបណាមួយមិនមាននោះឡើយ ។ ដូចនេះហើយ តើរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានផ្តល់គុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះមកដល់សង្គមជាតិ? តើរបបនេះចាប់ផ្តើមឡើងតាំងពីពេលណា ? ដោយសារអ្វី ? ហេតុអ្វីបានជាដួលរលំវិញ ? ដោយមូលហេតុអ្វី ? ហើយតើវិស័យសេដ្ឋកិច្ចនិងរបបសង្គមមានលក្ខណៈយ៉ាងណានៅក្នុងរបបនេះ ??? ជាពិសេសគឺភាពខ្លាំងនិងភាពខ្សោយដែលបានក៏កើតឡើងនៅក្នុងប្រទេសជាតិទាំងមូល។

# ជំពូកទី២
# ការលេចឡើងនៃបញ្ហាសាធារណរដ្ឋប្រជានិតកម្ពុជា
# (១៩៧៨ - ១៩៧៩)

## ២.១ បញ្ញាតផ្សេងៗនៅក្នុងអត្ថបទ ឬពាក្យគន្លឹះ

❋ *ប្រជាមានិត* = មានន័យថាដែលប្រជាជនចូលចត្តិស្រលាញ់រាប់អានដែលទាក់ទងដល់ប្រជារាស្ត្រដែលមានផលប្រយោជន៍ដល់បណ្ដាជនទូទៅ។

❋*ក៥* = មានន័យថា(កែន កង កម្លាំង កាប់ឆ្ការព្រៃ ការពារព្រំដែន កម្ពុជា)។

❋*ឧក្រិដ្ឋកម្ម* = ទោសកំហុសយ៉ាងធ្ងន់ធ្ងរបទល្មើសដ៏ធំ។

❋*បដិវត្តន៍* = ការវិលត្រលប់,ការប្រែប្រួល, ការកែប្រែឬ ផ្លាស់ប្ដូរ។ លាស់ទាន់កាលសម័យដើម , ការប្រព្រឹត្តប្រឆាំងដោយកំលាំងអាវុធចំពោះអំពើរំលោភចាប់ផ្ដើមបដិវត្តន៍ , អំពើរំលោភត្រូវបានសាបសូន្យដោយកំម្លាំងបដិវត្តន៍។

❋*ប្រជាធិបតេយ្យ* = ភាពនៃប្រទេសដែលមានប្រជារាស្ត្រជាអធិបតេយ្យគឺប្រទេស ឬ រដ្ឋបាលដែលមានប្រជាជនជាធំក្នុងការរើសតំណាងរបស់ខ្លួនឲ្យជាអ្នកសម្រេចកិច្ចការក្នុងប្រទេស...

❋*សន្និសីទ* = ពាក្យនេះតាមបាលីគឺមានន័យដូចគ្នាសន្និស័តដែរប៉ន្តែសព្វថ្ងៃនេះខ្មែរយើងប្រើសំដៅយកការប្រជុំគ្នាសំដែងពិភាក្សាអំពីបញ្ហាផ្សេងៗដែលបិតនៅក្នុងសភាពស្មុគស្មាញមិនទាន់ដាច់ស្រេចដើម្បីរិះរកផ្លូវចេញឬដោះស្រាយឲ្យជ្រះស្រឡះការថ្លែងសេចក្ដីពន្យល់អំពីបញ្ហាផ្សេងៗដល់សាធារណជនធ្វើសន្និសីទ , ធ្វើសន្និសីទ។

❋*ប្រតិកិរិយា* = ប្រើសំដៅយកផលដែលកាន់ជើងជួយជ្រោមជ្រែងដល់ប្រតិកម្មនយោបាយ ឬដល់បក្សពួកដែលប្រឆាំងចំពោះសេចក្ដីចម្រើនឬ ក៏ចំពោះគោលបំណងរបស់ខ្លួន។

❋*សាធារណរដ្ឋ* = រដ្ឋដែលអំណាចស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានាធិបតីឬសភា។

## ២.២ ការកកើតនៃបញ្ហា

ខ្មែរក្រហមបានធ្វើការគ្រប់គ្រងប្រជាពលរដ្ឋ ដោយអំពើគួរអោយភ័យខ្លាច អស់រយៈពេល៣ឆ្នាំ៨ខែ២០ថ្ងៃ។ អ្នកដែលបានរួចជីវិតពីរបប ប៉ុល ពត នៅចងចាំយ៉ាងច្បាស់ថា នៅក្នុងរបបនោះ សូម្បីតែសមាជិកគ្រួសារពេលខ្លះក៏មិនអាចនិយាយរកគ្នាបានដែរ សូម្បីតែឪពុកម្ដាយខ្លួនក៏ហ៊ានសំលាប់បានដែរ‌ចតែខ្លួនបានសុខដោយសារមានការភ័យខ្លាចនឹងសេចក្ដីស្លាប់ដែលកើតមានចំពោះពួកគេ ។បែបផែនការនេះនៃការគ្រប់គ្រងយ៉ាងតឹងរ៉ឹងរួមបញ្ចូលការដាក់កំហិត

លើចំណីអាហារ ប្រសិនបើមានអ្នកណាមួយមិនគោរពទៅតាមផែនការចាត់តាំងរបស់អង្គការនោះនឹងប៉ះពាល់ដល់ជីវិតរបស់ពួកគេជាមិនខាន ។

ការភ័យខ្លាចរបស់ប្រជាជនកម្ពុជា ឆ្លុះបញ្ចាំងឲ្យឃើញនូវភាពភ័យខ្លាចនឹងភាពឃោរឃៅរបស់មេដឹកនាំ ។ចាប់តាំងពីអំឡុងពេលសង្គ្រាមប្រឆាំងនឹងបារាំងចលនាកុម្មុយនីស្តកម្ពុជា មានកង្វះខាតនូវការឯកភាព និងជឿជាក់គ្នា ។ នៅឆ្នាំ១៩៦៣ សាឡុត ស (ប៉ុល ពត) បានចូលកាន់អំណាចគ្រប់គ្រងបក្សទាំងស្រុង ។ ការងាកទៅរកបដិវត្តន៍សង្គមនិយម ដោយងាកចេញឆ្ងាយពីវៀតណាម កាន់តែធ្វើឲ្យប៉ះទង្គិចដល់ជួរបក្ស ដែលធ្លាប់មានកិច្ចសហប្រតិបត្តិការជាមួយនឹងវៀតណាមផងដែរ ។ អំឡុងពេលជម្លៀសប្រជាជន ចេញពីទីក្រុងភ្នំពេញយើងបានឃើញថា មានក្រុមទាហានខ្មែរក្រហមខ្លះ ស្លៀកពាក់ពណ៌ប្រផេះខ្លះទៀតស្លៀកពាក់ពណ៌ខ្មៅសុទ្ធ ។ សេចក្តីរាយការណ៍សម្ងាត់ឆ្នាំ១៩៧៩ របស់សមាជិកការិយាល័យនយោបាយបក្សកុម្មុយនីស្តចិនលោក ចេង បៀវ បាននិយាយថាយ៉ាងណាពួកកុម្មុយនីស្តខ្មែរ ក៏មានបីក្រុមដែរក្នុងពេលដែលជ័យជំនះឆ្នាំ១៩៧៥:"ប្រសិនបើ ត្រូវបានគ្រប់គ្រងល្អនៅពេលកងទ័ពកម្ពុជា ចាប់ផ្តើមបង្រួបបង្រួមក្នុងឆ្នាំ១៩៧៦ នោះស្ថានភាពនឹងមិនអាក្រក់ទេ ។ ប៉ុន្តែបក្សកុម្មុយនីស្តកម្ពុជាពុំបានធ្វើតាមវិធីត្រឹមត្រូវក្នុងការគ្រប់គ្រងពួកគេទេ ហេតុនេះហើយទើបអោយឈានដល់ការមិនចុះសម្រុងគ្នាឈានដល់ការបែកបាក់ "។

**ក្រុមទី១(ក្នុងការវិភាគរបស់ ចេង បៀវ)**គឺជាក្រុម ទាហានចាស់ ដែលគាំទ្រ សីហនុ ក្នុងរណសិរ្សបង្រួបបង្រួមជាតិខ្មែរក្រោមឆ្នាំ១៩៧០ និងជាអ្នកមិនសប្បាយចិត្តនឹងអ្នកទទួលជោគជ័យ ហើយធ្វើអំពើមិនល្អចំពោះសម្តេចព្រះ នរោត្តម សីហនុ ។ពួកនេះក៏ ត្រូវបានគេដាក់ទោសចំពោះភាពរឹងរូសរបស់ខ្លួន និងត្រូវគេចាត់ទុកជាកងទ័ព ឬគ្រួសារប្រតិកិរិយា។ ចំណុចនេះធ្វើអោយអ្នកគាំទ្របក្សកុម្មុយនីស្តដំបូង ធ្វើការបះបោរ និងងាកទៅចូលក្នុងកងទ័ពរបស់លន់ នល់ និងក្លាយជាកងទ័ពប្រឆាំងចលនាបដិវត្តន៍ទៅវិញ ។

**ក្រុមទី២** គឺជាក្រុមដែលលំអៀងទៅវៀតណាម ។ក្រុមនេះមានគ្នាប្រហែលច្រើនបួនពាន់នាក់ ហើយស្ថិតក្នុងភាពគេកាប់សម្លាប់ចាប់ដាក់គុកពោលគឺ ជីវិតរបស់ពួកគេស្ថិតក្នុងភាពគំរាមកំហែង ហើយពួកគេបានធ្វើការបះបោរឡើង ប្រឆាំងនឹងមេដឹកនាំកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ ។

**ក្រុមទី៣(ក្រុមទទួលជោគជ័យ)** គឺជាក្រុមដែលលំអៀងទៅខាងចិន ប៉ុន្តែហាក់ដូចជាមិនចុះសម្រុងក្នុងក្រុមរបស់ខ្លួន។"បដិវត្តន៍វប្បធម៌ពលករដ៏អស្ចារ្យ"បានពាក់ពន្ធ័នឹងប្រទេសចិនក្រោយមានរលកនៃការកែប្រែមនោគមវិជ្ជាពីឆ្នាំ១៩៦៦។រហូតដល់មានការចាប់ខ្លួន មេក្បត់បួននាក់នៅប្រទេសចិនក្នុងខែតុលាឆ្នាំ១៩៧៨។

ទសវត្សនៃបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងដំណាក់កាលនៃការតស៊ូប្រដាប់អាវុធ ហើយក្រោយមកបានទទួលជោគជ័យ នឹងកាន់អំណាច បានកើនឡើងព្រមគ្នានឹងទសវត្សរបស់ចិននៅក្នុងបដិវត្តន៍វប្បធម៌។ក្នុងខណៈពេលនោះតើមានអ្វីប្រែប្រួលនៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានលំអៀងទៅខាងចិន?

លោក **បេន គៀរណាន** ក៏ជឿជាក់ថា មានបីក្រុមសំខាន់ៗក្នុងចលនាបក្សកុម្មុយនីស្តកម្ពុជា ក្នុងអំឡុងទសវត្សឆ្នាំ១៩៦០ និង១៩៧០:

ក្រុម**អ្នកជាតិនិយមហួសហេតុ** ដែលដឹកនាំដោយ ប៉ុល ពត ដែលមានមធ្យោបាយដឹកនាំតាមទំនៀមទំលាប់និយមដែលមិនខុសពីរបបលន់នល់។

ក្រុម **ហ៊ូ នឹម** ដែលមានទំនាញទៅរកមនោគមវិជ្ជា ប្រជាធិបតេយ្យមហាជន ដែលត្រូវបានអនុវត្តនៅក្នុងបដិវត្តន៍វប្បធម៌ក្នុងប្រទេសចិន។

ក្រុម **នង សួន កែវមុនី និង សោ ភឹម** ដែលមានទំនោររកការកសាងសង្គមនិយមយកតាមម៉ូដែល សង្គមនិយមវៀតណាម។

ក្រោយឆ្នាំ១៩៧០ បេន គៀរណាន បាននិយាយថា ក្រុមទាំងនេះ បានបោះទីតាំងផ្សេងគ្នាទៅតាមនិន្នាការនយោបាយ។ ក្រុមលំអៀងខាងវៀតណាមស្ថិតនៅភាគខាងកើត។ ដូច្នេះយើងឃើញថាអំណាចរបស់ ប៉ុល ពត ស្ថិតក្នុងភាពគ្រោះថ្នាក់នៅពេលដែលខាង ក្រុមផ្សេងទៀតដាក់សម្ពាធ ។ អ្វីដែលលោក បេន បៀវ និងបេន គៀរណានបានធ្វើការបែងចែកក្រុមកុម្មុយនីស្តខ្មែរនេះ អាស្រ័យទៅលើកិច្ចសហប្រតិបត្តការរបស់មេដឹកនាំក្រុមនីមួយៗ ជិតស្និទ្ធជាមួយនឹងអ្នកណាតែប៉ុណ្ណោះ។ ទោះជាយ៉ាងណាក្តី គេមានចរន្តឯកភាពមួយរួមគ្នា គឺការធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ។ ប៉ុន្តែនៅក្នុងដំណាក់កាលតស៊ូឆ្នាំ១៩៧០- ១៩៧៥ និងក្រោយឆ្នាំ១៩៧៥ នៅពេលប៉ុល ពត និងគូកនបានពង្រឹងអំណាចកំពូលបានហើយ យើងឃើញមានការបោសសម្អាតពួកដែលនៅក្នុងក្រុមផ្សេងទៀត ជាពិសេសនៅពេលដែលផ្ទុះសង្គ្រាមជាមួយវៀតណាម។

**ក. ការបះបោរ**

ការប្រឆាំងនឹង ប៉ុល ពត តែងតែកើតមានឡើងជារឿយៗក្នុងរយៈពេលប៉ុន្មានឆ្នាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សាយ ភូថង ជាអតីតមេដឹកនាំឥស្សរៈម្នាក់ ដែលក្លាយជាប្រធានគណៈចាត់តាំងមជ្ឈិមនៃបក្សប្រជាជនបដិវត្តន៍កម្ពុជាក្រោយឆ្នាំ១៩៧៩ បានចូលរួមនឹងក្រុមបះបោរប្រឆាំងនឹងពួកខ្មែរក្រហម តាំងពីឆ្នាំ១៩៧៤ មកម្លេះ នៅក្នុងខេត្តកោះកុង ។

ការបះបោរលើកទី១ ប្រឆាំងនឹងរបបនេះបានធ្វើឡើងនៅខេត្តសៀមរាបនៅក្នុងខែកញ្ញាឆ្នាំ១៩៧៥ ប៉ុន្តែត្រូវបានត្រូវគេបង្ក្រាបដូចការបះបោរនៅខេត្តបាត់ដំបង ខេត្តកណ្តាល ខេត្ត

សៀមរាប និងខេត្តកោះកុងនៅក្នុងឆ្នាំបន្តបន្ទាប់ទៀតដែរ ។ សកម្មភាពនៃការបះបោរនេះហាក់ពុំមានប្រសិទ្ធភាព ប៉ុន្តែបានធ្វើឲ្យរបបនេះភិតភ័យ និងគ្មានសុវត្ថិភាព ។ ព្រឹត្តិការណ៍នៅខេត្តសៀមរាប ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៦ បានធ្វើអោយរបប នេះត្រូវគេរិះគន់ ឬតិះដៀលដោយសហរដ្ឋអាមេរិក ។នាថ្ងៃនោះ ក្រុងសៀមរាប ត្រូវទទួលការទម្លាក់គ្រាប់បែក ដោយយន្តហោះពីគ្រឿង បានទម្លាក់ក្នុងរយៈពេល៦ម៉ោង ។ កម្ពុជាប្រជាធិបតេយ្យបានធ្វើការប្រកាសថា មនុស្ស ១៥នាក់បានស្លាប់ ហើយ៣០នាក់ផ្សេងទៀតបានរងរបួសធ្ងន់ ហើយគេបានអះអាងថា ការទម្លាក់នេះត្រូវបានធ្វើឡើងដោយយន្តហោះ USF 111 ពេលទម្លាក់រួច ក៏ហោះលាក់ខ្លួនចូលទឹកដីថៃបាត់ទៅ ។អ្នកដឹងឮនូវព្រឹត្តិការណ៍នេះ (ជនជាតិខ្មែរ)នៅខណៈពេលនោះមានការសង្ស័យលើ Thai Air Force, Viet-nam MIGS ឬChinesebuilt MIGS ពីទីក្រុងភ្នំពេញ ។ ប៉ុន្តែនៅចុងខែធ្នូ ឆ្នាំ១៩៧៨ ពីសប្តាហ៍មុនពេលដែលកងទ័ពវៀតណាម ធ្វើការវាយកម្ទេចរបបប៉ុល ពត កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យបានប្រាប់ទៅម៉ាល់កូម( )ដែលបានធ្វើសាក្សី ចំពោះអំពើឃោរឃៅដែលបានកើតមាននៅកម្ពុជាថា យើងមានភស្តុតាង វាមិនពាក់ព័ន្ធនិងវៀតណាមទេ គឺសេ អ៊ី អាជាអ្នកធ្វើ និងភ្នាក់ងារនៅក្នុងប្រទេសថៃ ។នៅថ្ងៃទី២ខែមេសា ឆ្នាំ១៩៧៦ ជាថ្ងៃដែលសម្តេចព្រះ នរោត្តម សីហនុ បានបដិសេធកាន់តំណែងជាប្រមុខរដ្ឋ គ្រាប់បែកដាក់ជាច្រើនគ្រាប់បានផ្ទុះនៅជិតព្រះបរមរាជវាំងក្នុងទីក្រុងភ្នំពេញ ហើយមានការបាញ់ប្រហារនៅជិតសារមន្ទីជាតិ នៅជិតបរិវេណរបស់មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ។ក្នុងការវាយប្រហារនោះ ហាក់ដូចគ្មានអ្នកស្លាប់ ឫរងរបួសនោះទេហើយក៏គ្មានការខូចខាតអ្វីដែរ ។ ១០ថ្ងៃក្រោយមកជនសង្ស័យត្រូវចាប់ខ្លួន និងសាកសួរនៅមន្ទីរឃុំឃាំង ស ២១ ដែលជាទីបញ្ជាការកណ្តាលរបស់ក្រុមប៉ុលីស សន្តិសុខ ឫហៅថា មន្ទីរសន្តិបាល ។ តាមលទ្ធផលនៃការសារភាពរបស់ ច័ន្ទ ចក្រី ដែលជានាយសេនាធិការនយោបាយនៃកងពលលេខ១៧០ និងលេខាធិការរងនៃកងទ័ពជាតិទើបបង្កើតថ្មី បានត្រូវចាប់ខ្លួននិងចោទថា បានចូលរួមក្បត់ក្នុងការធ្វើរដ្ឋប្រហារ ។ បន្ទាប់ពីការសាកសួរ ចក្រី អស់ជាច្រើនខែប្រធានសន្តិបាល ឈ្មោះ ឌិច បានរាយការណ៍ទៅ ប៉ុល ពត ថាគាត់បានរកឃើញអង្គការចារកម្មដ៏ធំមួយ ដែលគាត់ហៅថា បណ្តាញខ្សែរយៈចោរ ដែលសំដៅលើក្រុមភូមិភាគបូព៌ា ដែលមាន សោ ភឹម ជាលេខាធិការ ។

មានកំណត់ត្រាមួយចំនួន បាននិយាយពីការបះបោរប្រឆាំងនឹងរបប ប៉ុល ពត និងការផ្ទុះចេញនូវកំហឹងរបស់ប្រជាជន ដូចបានកើតឡើងនៅស្រុកជីក្រែង ភាគអាគ្នេយ៍នៃក្រុងសៀមរាបនៅក្នុងខែមិនា ឆ្នាំ១៩៧៧និងនៅក្នុងស្រុកស្ទោង ខេត្ត កំពង់ធំ ។កំហឹង ការភ័យខ្លាច និងបែកបាក់ បានបង្ហាញនូវភាពគ្មានអំណាចរបស់ប្រជាជនរងគ្រោះ ។ សកម្មភាពប្រឆាំងជា

ច្រើនបានកើត និងមានអ្នកនៅរស់ជាច្រើន បានចងចាំនូវការស្រែកទ្រហោរយំនឹងការឈឺចាប់របស់អ្នកទោស ពីក្នុងរទេះគោ ដែលដឹងពួកគេយកទៅសម្លាប់ ប៉ុន្តែសកម្មភាពប្រឆាំងទាំងនេះហាក់ដូចជាបង្ហាញឲ្យឃើញនូវភាពអស់សង្ឃឹមតែប៉ុណ្ណោះ ។ នៅពេលបះបោរបានសម្រេចជោគជ័យជាចុងក្រោយ គឺស្ថិតនៅតំបន់ភាគបូព៌ា ឥសានតំបន់ដែលលន់ នល់ មិនធ្លាប់បានធ្វើការគ្រប់គ្រង និងតំបន់ដែលវៀតកុងធ្វើការហ្វឹកហ្វឺនខាងយោធានិងនយោបាយដល់កម្លាំងបដិវត្តន៍ខ្មែរ ក្នុងសង្គ្រាមឥណ្ឌូចិនលើកទី១ប្រឆាំងនឹហសហរដ្ឋអាមេរិក ។ នៅក្នុងខែវិច្ឆិកាឆ្នាំ១៩៧៧ ការបះបោររបស់កងវីរសេនាធំលេខ១៥៥ ដែលដឹកនាំដោយ ណុម សាមុត នៅក្នុងខេត្តព្រៃវែង បានរាលដាលដល់ខេត្តទាំង៨ ហើយនៅខែ ឧសភា កងកម្លាំងបះបោរបានបង្កើតកម្លាំងរំដោះជាច្រើន ។ កែវ ចិន្តាជារដ្ឋមន្ត្រីទី១នៃក្រសួងព័ត៌មាន និងវប្បធម៌នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានប្រាប់ទៅអ្នកការសែត ដែលមកធ្វើទស្សនះកិច្ចនៅខែកុម្ភះឆ្នាំ១៩៧៩ថាគាត់បានបោះទីតាំងនៅតំបន់រំដោះភាគឥសាន ជាច្រើនខែមុនការរំដោះ ហើយការរស់នៅក្នុងទីនោះមានស្ថិរភាពចាប់តាំងពីចុងឆ្នាំ១៩៧៨ ហើយមានការស្ថាបនាសាលារៀនមន្ទីពេទ្យ និងដំណើរការជាប្រក្រតី ។ អ្នកចូលរួមការបះបោរ ដូចដែលបានពណ៌នាដោយ កែវ ចិន្តា អាចនៅសេសសល់ច្រើន ។ ប៉ុន្តែពួកបះបោរភាគច្រើននៅភាគបូព៌ា ត្រូវបានបង្ក្រាបយ៉ាងឃោរឃៅ ដោយកម្លាំងទ័ពមជ្ឈិមរបស់កម្ពុជាប្រជាធិបតេយ្យដែលទទួលបានការគាំទ្រពីកម្លាំងភាគនិរតី ។ កម្លាំទ័ពក្នុងភាគនិរតីប្រហែលជាង១០ពាន់នាក់ត្រូវបានជម្លៀសទៅភាគពាយ័ព្យនៅក្នុងឆាកបង្ហូរឈាមនៃរបបនេះ ។ប៉ុន្តែលទ្ធផលនៃការបះបោរនេះហាក់ទទួលបានលទ្ធផលផ្សេងទៅវិញ ពីព្រោះអ្នកនៅរស់ជាច្រើននាក់ ទាំងនាក់រត់គេចទៅវៀតណាម ឬអ្នក ដែលអនាគតនឹងក្លាយទៅជាប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាមិនិត្យកម្ពុជា (ហេង សំរិន) ត្រូវបានការពារដោយកងកម្លាំងទ័ពវៀតណាមនៅក្នុងខែឆ្នាំ១៩៧៨។បួនខែក្រោយមកពួកគេបានត្រលប់មកវិញ និងរួមជាមួយនឹងកងទ័ពវៀតណាមផងនោះ មកផ្តួលរលំរបប ប៉ុល ពត ។

## ខ. សង្គ្រាមជាមួយវៀតណាម

- **ប្រភពនិងដំណើរវិវត្តន៍នៃទំនាស់**

ភាពភ័យខ្លាចនិងការត្រូបាក់លេបយកប្រទេសជាតិខ្លួន ដោយប្រទេសជិតខាង គឺជាចំណុចមួយនៃការព្រួយបារម្ភរបស់អ្នកជាតិនិយមក្នុងប្រទេសកម្ពុជា ។លេចឡើងនូវភាពភ័យខ្លាចមួយថា ប៉ុល ពត ធ្លាប់បានបង្កភាពកាចសាហាវ នៅក្នុងអំឡុងប៉ុន្មានឆ្នាំនៃអំណាចរបស់គាត់ ។ ការបះទង្គិចគ្នាដោយទំនាស់ដែនដីរវាងកម្ពុជា និងវៀតណាម តែងតែកើតមានក្នុងចន្លោះឆ្នាំ១៩៧៥ និង១៩៧៧ ហើយភាពតានតឹង កាន់តែឈានទៅដល់ចំណុចកំពូលក្នុងឆ្នាំ

១៩៧៨ ។ បន្ទាប់ពីមានការដកទ័ពវៀតណាមថយចេញពីប្រទេសកម្ពុជាក្រោយខែតុលាឆ្នាំ ១៩៧២ មានការវាយប្រហារលើកងទ័ពវៀតណាម និងមន្ត្រីវៀតណាម ហើយសហរដ្ឋអាមេរិក បានទម្លាក់គ្រាប់បែកធុន B-52ប្រឆាំងអ្នកបះបោរកុម្មុយនីស្តកម្ពុជា និងទំនាក់ទំនងរវាងបក្ស ពលករវៀតណាម និងបក្សកុម្មុយនីស្តកម្ពុជាបានដល់ទី បញ្ចប់ ។ នៅក្នុងការសន្ទនាជាមួយនឹង អ្នកការទូតសុវៀត ឡេយន់ បានធ្វើសេចក្តីរាយការណ៍ថា ការផ្តើមគំនិតក្នុងកិច្ចការរបស់ ប្រជាជនកម្ពុជា មិនទាក់ទងជាមួយយើងទេ ។ គាត់បានបន្តទៀតថា បក្សបដិវត្តន៍របស់ ប្រជាជនកម្ពុជាមានការទាស់ទែងទាំងជាមួយសីហនុ និងសមាជិករបស់ខ្លួន ។អង្គការរបស់ពួក គេមានទីតាំងនៅប៉េកាំង ។ ស្ថានទូតចិនប្រចាំហាណូយមានទំនាក់ទំនងច្រើនជាមួយពួកគេ ច្រើនជាងយើង ប៉ុន្តែសមមិត្តខ្មែរមានការប្រុងប្រយ័ត្នខ្លាំងណាស់ ។ ចំនួយរបស់យើងចំពោះ ពួកគេគឺ មានភាពសំខាន់ និងរឹងមាំ ដូច្នេះយើងអាចកាន់តែជិតស្និទ្ធនឹងពួកគេ ។លទ្ធភាពដែល អាចជិតស្និទ្ធនិងពួកគេនេះគឺធ្វើឡើងតាមរយៈការត្រួតត្រាទៅលើ ផ្លូវហូជីមិញហើយជាផ្លូវ ដែលចិនធ្វើការផ្គត់ផ្គង់ទ័ព អាចមកដល់ប្រទេសកម្ពុជា ។ លោក ម៉ាស្សាកូវ កត់សម្គាល់ថាចាប់ ពីឆ្នាំ១៩៧៤ ទំនាក់ទំនងល្អរវាងបក្សពលករវៀតណាម និងបក្សកុម្មុយនីស្តកម្ពុជា អាស្រ័យលើ កម្រិតកិច្ចសហការគ្នា និងក្នុងការត្រៀមរៀបចំ ដើម្បីកាប់ទីក្រុងភ្នំពេញ ។ នៅឆ្នាំ១៩៧៥ វៀត ណាមបានធានា ផ្តល់ជំនួយឥតសំណងដល់កងទ័ពកម្ពុជា ។នេះគឺជារឿងគួរអោយចាប់ អារម្មណ៍ចំពោះវៀតណាមខាងជើង ដែលធ្វើអោយមានសង្គ្រាមស៊ីវិលក្នុងប្រទេសកម្ពុជារហូត ដល់ខ្លួនឯង អាចរៀបចំផែនការចប់សព្វគ្រប់ ក្នុងការរៀបចំវៀតណាមខាងត្បូង ។ វាក៏បាន បង្ហាញផងដែរថា វៀតណាមពុំបានរៀបចំផ្តាចទំនាក់ទំនងទាំងស្រុងជាមួយបក្សកុម្មុយនីស្ត កម្ពុជានោះទេ ។

នៅឆ្នាំ១៩៧៥ បន្ទាប់ពីជោគជ័យរបស់ពួកកុម្មុយននីស្តនៅក្នុងសង្គ្រាមឥណ្ឌូចិន ប៉ុល ពត បានធ្វើទស្សនកិច្ចនៅទីក្រុងហាណូយ ហើយគាត់បានធ្វើការបដិសេធយ៉ាងទន់ភ្លន់ នូវ ទំនាក់ទំនងពិសេសជាមួយនឹងវៀតណាម ។

ការប៉ះទង្គិចគ្នាក្នុងរឿងព្រំដែន និងការយល់ខុសចំពោះគ្នា តែងតែកើតមានជាញឹកញាប់ រវាងរដ្ឋទាំងពីរ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។អំពើឃោរឃៅនៅតាមព្រំដែន បានកើត មានលើភូមិវៀតណាមនៅពាក់កណ្តាលឆ្នាំ១៩៧៧ដែលធ្វើអោយកាន់តែអាក្រក់នូវទំនាក់ទំនង អំណាចជាមួយនឹងកូនខ្មែរកាត់វៀតណាម ហើយ ការលេចឡើងនូវកងយោធាចិន ដែលធ្វើការ ហ្វឹកហ្វឺនកម្លាំងខ្មែរក្រហមស្ថាបនាផ្លូវ និងមូលដ្ឋានយោធាបានក្លាយជាការគម្រាមកំហែងជាថ្មី ម្តងទៀត ចំពោះសន្តិសុខរបស់វៀតណាម ។

## ២.៣ ការប្រឆាំងរបបកម្ពុជាប្រជាធិបតេយ្យ និងការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតកម្ពុជា

បន្ទាប់ពីមានការតស៊ូបះបោរប្រឆាំង និងរបប ប៉ុល ពត នៅឆ្នាំ ១៩៧៦ របស់ប្រជាជននៅចម្ការហ្លួងសៀមរាបនិង នៅឆ្នាំ១៩៧៧ របស់ប្រជាជននៅភាគខាងជើងខេត្តសៀមរាប និងប្រជាជននៅខេត្តបាត់ដំបងហើយនៅឆ្នាំ១៩៧៧ ខែមេសាក៏មានការតវ៉ារបស់ប្រជាជន នៅខេត្តកំពង់ធំ មណ្ឌលគីរី និងកំពង់ឆ្នាំង ។

នៅថ្ងៃទី ២ ខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិបានបង្កើតឡើងនៅ ស្នួល ខេត្តក្រចេះ ដែលជាមហាសន្និបាត តំណាងកំលាំងរំដោះទូទាំងប្រទេស ។ នៅពេលនោះមហាសន្និបាត បានសម្រេចបោះឆ្នោតជ្រើសតាំង គណៈកម្មាធិការមជ្ឈិមរណសិរ្ស ដែលមានសមាជិក ១៩រូប ដែលមានលោក ហេង សំរិន ជាប្រធាន ។ ពេលនោះមហាសន្និបាតបានអនុម័តដាក់ចេញ នូវកម្មវិធីនយោបាយរបស់រណសិរ្ស ជាមាគ៌ា ភារកិច្ច និងគោលការណ៍សង្គ្រោះជាតិគឺគោរពឆន្ទ និងគោលបំណងរបស់ប្រជាជន ផ្តួលរំលំពួកប្រតិកិរិយា ប៉ុល ពត ដែលជាឃាតករ និងកសាងលប្រទេសកម្ពុជាប្រកបដោយ សន្តិភាព ឯករាជ្យ ប្រជាធិបតេយ្យ អព្យាក្រឹត និងសម្បូររុងរឿង ។កម្មវិធីនយោបាយ ១១ ចំណុចបានកំណត់នូវកិច្ចការជាទិសដៅសម្រាប់របបថ្មី ។ ការប្រមូលផ្តុំ(យុវជន យុវនារី សហជីព កសិករ បញ្ញាវន្ត ) និងការបង្កើតឡើងជាមួយនឹងទស្សនវាយកំទេចពួកប្រតិកិរិយា ប៉ុល ពត អៀង សារី និងការនាំមកនូវសិទ្ធិប្រជាពលរដ្ឋក្នុងការគ្រប់គ្រងប្រទេសរបស់ខ្លួន ។ បន្ទាប់ពីកិច្ចប្រជុំនៅស្នួលកងកម្លាំងរណសិរ្ស បានធ្វើដំណើរចូលតាមភូមិ តាមព្រំប្រទល់ដើម្បីពន្យល់នូវកម្មវិធី ១១ ចំណុចនេះនិងធ្វើការឧបត្ថម្ភដល់ប្រជាពលរដ្ឋ ។ សន្លឹកបណ្ណ័តូចៗត្រូវបានទម្លាក់ពីយន្តហោះវៀតណាម នៅលើទឹកដីកម្ពុជា តាមភូមិប្រជាជនដែលនៅជាប់ព្រំប្រទល់និងវៀតណាម ដើម្បីបង្ហើយហៅឲ្យមានអ្នកបះបោរឡើង ហើយស្ថានីវិទ្យុ(សម្លេងប្រជាជនកម្ពុជាក្នុងក្រុងហាណូយបានធ្វើការផ្សព្វផ្សាយនូវពត៌មានដូចគ្នានេះដែរ ។

ការវាយប្រហាររបស់កងទ័ពប្រជាជនវៀតណាម មកលើកងទ័ពកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមជាសន្ទឹកសន្ទាប់ជាទ្រង់ទ្រាយធំ នៅពាក់កណ្តាលយប់ថ្ងៃទី ២៤ ធ្នូ ១៩៧៩ ។ កងទ័ព ១៥០ពាន់នាក់បានធ្វើដំណើរយ៉ាងរហ័សតាមផ្លូវសំខាន់ៗតម្រង់ទៅកាន់ទីក្រុងភ្នំពេញដែលនាំមុខដោយរថក្រោះផលិតដោយសហភាពសូវៀត ។ នៅថ្ងៃទី ០៤ មករា ១៩៧៩ ពួកគេបានគ្រប់គ្រងដែនដីកម្ពុជាភាគខាងកើតទន្លេមេគង្គទាំងអស់ ។ នៅថ្ងៃទី ០៦ ខែ មករា ពួកគេបានឆ្លងកាត់ទន្លេ ហើយបានកាន់កាប់តំបន់តាមដងទន្លេ បន្ទាប់មកពួកគេបានចូលកាន់កាប់

តំបន់ជាយៗក្រុងភ្នំពេញ ។ កម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា មានចំនួនគ្រប់គ្រាន់សម្រាប់បង្កើតជាក្រុមទព័ស្រួចមួយនៅក្នុងជួរជាមួយកងទព័ប្រជាជនវៀតណាមតែប៉ុណ្ណោះ ហើយមានចំនួនមិនលើសពីនេះទេ ដើម្បីវាយលុកផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ។ ហ៊ុន សែន បានពន្យល់ថា *ពេលបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាកម្លាំងរបស់យើងមានប្រមានប្រហែល ៣០ កងវរសេនាតូច...ពិនិត្យលើចំនួននេះឃើញជាច្រើនបង្គួរ ប៉ុន្តែបើប្រៀបធៀបនិងកងទព័របស់ពួក ប៉ុល ពត ២៣កងពលធំឃើញថាតិចណាស់* ។ តែដោយមានការបែកបាក់ផ្ទៃក្នុងនិងមានការកាប់សម្លាប់ប្រជាជន ហើយដោយមានការជួយពីកងទព័ស្ម័គ្រចិត្តវៀតណាម និងកងកម្លាំងប្រដាប់អាវុធរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានធ្វើឲ្យរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅថ្ងៃ ៧ មករា ១៩៧៩ ។ដោយបានធ្វើការរំដោះចាប់ពីចុងខែ ធ្នូ ១៩៧៨ ដល់ ៧ មករា ១៩៧៩ ទើបប្រទេសកម្ពុជារំដោះផុតទាំងស្រុងពីរបប ប៉ុល ពត ។ ហ៊ុន សែន បានបន្តទៀតថា "*ទោះបីជាជោគជ័យថ្ងៃ៧ មករា ១៩៧៩ ត្រូវបានប្រើកម្លាំងពីរតួបផ្សំគ្នាគឺកម្លាំងជាតិ និងការជួយឧបត្ថម្ភពីកងទ័ពស្មគ្រចិត្តវៀតណាម ។ កងទ័ពស្មគ្រចិត្តវៀតណាមបានដើរតួរយ៉ាងសំខាន់ក្នុងការវាយប្រហារកំចាត់ពួក ប៉ុល ពត ក៏ដោយក៏កងកម្លាំងបដិវត្តន៍កម្ពុជាមានតួរនាទីជាអ្នកកំណត់ ពិព្រោះបដិវត្តន៍ណាមួយទទួលបានជោគជ័យក្នុងប្រទេសមួយ វាត្រូវតែជាប្រជាជននៃប្រទេសនោះ ដែលជាអ្នកធ្វើសកម្មភាព ហើយគ្មានប្រទេសផ្សេងទៀតអាចមកជំនួសបានទេ ។ ការឧបត្ថម្ភរបស់វៀតណាមគឺជាការឆ្លើយតបនៃការស្នើរសុំរបស់ប្រជាជនកម្ពុជា*"។ ពេលនោះប្រទេសបានរួចផុតពីស្បែងងឹត ហើយប្រជាជនបានវិលមកស្រុកកំនើតវិញ រីឯអ្នកខ្លះទៀតបានទៅដល់ប្រទេសផ្សេងៗ តាមរយះអង្គការសហប្រជាជាតិសំរាប់ជនភៀសខ្លួន ។ ពេលមកដល់ស្រុកកំណើតវិញអ្នកខ្លះបានជួបបងប្អូន អ្នកខ្លះមិនបានជួបទេព្រោះពួកគេបានស្លាប់អស់ទៅហើយ ។ ប៉ុន្តែអ្នកមកដល់សុទ្ធតែជាមនុស្សចាស់ ស្ត្រីមេម៉ាយ ពួកគេបានធ្វើការប្រវាស់ដៃគ្នា ពីព្រោះពួកគេគ្មានឧបករណ៍សំរាប់បង្ករបង្កើនផលនោះទេ ហើយនៅតាមភូមិនីមួយៗ គេបែងចែកជាក្រុមដែលមួយក្រុមៗមានប្រហែល ១០គ្រួសារ និងមានគោ ក្របី ជាកម្លាំងអូសទាញដែលសល់ពីរបប ប៉ុល ពត ។ តាមគោលការណ៍របស់សាធារណរដ្ឋកម្ពុជាបានប្តូរពីក្រុមមកជារបបកម្មសិទ្ធិឯកជនវិញ ។

# ជំពូកទី ៣

# ដំណើរការវិត្តនៃបញ្ហាមុននិងដល់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា

## ៣.១ ស្ថាប័នអំណាច និងអង្គការគ្រប់គ្រងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា

### ក. លក្ខណៈទូទៅនៃស្ថាបន័អំណាចថ្មី

ប្រពន្ធ័អំណាចក្នុងប្រទេសកម្ពុជានៅដំណាក់កាល ១៩៧៩ ដល់ ១៩៨៨ត្រូវបានបង្កើតឡើងដោយសន្សឹមៗ និងមួយដំណាក់កាលម្តងៗ ។ ដំនើរវិវត្តន៍នៃការកសាងអំណាចនេះបានឆ្លងកាត់នូវការលំបាក និងភាពស្មុគស្មាញយ៉ាងច្រើនដែលយើងអាចបែងចែងជា២ដំណាក់កាល ៖

- *ការលេចឡើងនូវស្ថាបន័អំណាចរដ្ឋ នៅប្រទេសដែលបានបង្កើតឡើងពិសេសក្នុងដំណាក់កាល ១៩៧៩ ដល់ ១៩៨១*
- *នៅពេលដែលបង្កើតឡើងនូវរចនាសម្ព័ន្ធបក្សជាអង្គដឹកនាំសង្គមទាំងស្រុង* ។ ដំណាក់កាលនេះអាចកំណត់បាននៅពេលដែលប្រារព្ធមហាសន្និបាតបក្សប្រជាជនបដិវត្តន៍កម្ពុជាលើកទី ៥ ហើយរហូតដល់ឆ្នាំ ១៩៩៣ ។

### ខ. ការកសាងស្ថាបន័រដ្ឋ និងការគ្រប់គ្រង

ក្រសួងសំខាន់ត្រូវបានកាន់កាប់ដោយអ្នកតស៊ូចាស់ៗនៅភូមិភាគបូព៌ាពិសេស គឺមកពីខេត្តកំពង់ចាម ស្វាយរៀង និងអ្នកមកពីហាត់នៅប្រទេសវៀតណាមក្រោយសន្ធិសិទ្ធិហ្សឺណែវ ១៩៥៤ ដែលមានតួនាទីជារដ្ឋមន្ត្រីនៅក្នុងក្រសួងមហាផ្ទៃ ការពារជាតិឬក្នុងជួរគណៈកម្មាធិការប្រជាជនបដិវត្តន៍ខេត្ត/ក្រុង ។ ក្រោយពីសន្តិភាពមានលំនឹង គេចាប់ផ្តើមគិតពីសមត្ថភាព ចំនេះដឹងដែលសេសសល់ពីរបបសង្គមរាស្ត្រនិយម លន នល់ ដូចជាវិស្វករ អ្នកបច្ចេកទេស និស្សិត សាស្ត្រាចារ្យ កម្មករ តែមនុស្សសំខាន់នៅក្នុងជួររដ្ឋាភិបាលមាន លោក ហ៊ុន សែន ជា ស៊ីម និង ហេង សំរិន ដែលជាអ្នកតស៊ូចេញពីវណ្ណៈកម្មករ និងកសិករ ។

ចំពោះរចនាសម្ពន្ធ័រដ្ឋអំណាចកម្ពុជា ត្រូវបានបង្កើតឡើងក្នុងដំណាក់កាលពីឆ្នាំ ១៩៧៩ ដល់ ១៩៨១ ។ ជាលើកទី ១ បន្ទាប់ពីជោគជ័យលើពួក ប៉ុល ពត នៅថ្ងៃ៧ មករា ១៩៧៩ មកអំណាចនីតិបញ្ញាត្តិ និងអំណាចនីតិប្រតិបត្តិ ស្ថិតនៅក្រោមការគ្រប់គ្រងពីសំណាក់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ។ មូលដ្ឋាននៃក្រុមប្រឹក្សាបដិវត្តន៍កម្ពុជា កើតចេញពីរណសិរ្យសាមគ្គីសង្គ្រោះជាតិ ដែលជាអង្គការមួយបណ្តុំទៅដោយមហាជនគ្រប់ស្រទាប់វណ្ណៈនៅក្នុងទិសដៅតស៊ូនិងពួក ប៉ុល ពត ។ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាជាប្លុកប្រជាធិបតេយ្យមួយ ដែល

ចូលរួមទៅដោយមនុស្សផ្សេងៗ ដោយមិនប្រកាន់និន្នាការនិងអតីតភាព ។ របបសម្ពន្ធ័ដឹកនាំប្រទេសកម្ពុជាមានលក្ខណៈពិសេសរបស់ខ្លួន ជាដំបូងគេ រៀបចំក្បាលម៉ាស៊ីនដឹកនាំរដ្ឋបាលថ្នាក់លើ នៅពេលជាមួយគ្នានេះដែរ របបសម្ពន្ធ័ដឹកនាំថ្នាក់ក្រោមសឹងតែគ្មានសោះតែម្តង ។ នាពាក់កណ្តាលឆ្នាំ ១៩៧៩ ការសែត កម្ពុជា បានសរសេរ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា និង រណសិរ្សសង្គ្រោះជាតិ បានដាក់កម្មវិធីបង្កើតគណៈកម្មាធិការប្រជាជនបដិវត្តន៍ ភូមិ ឃុំ ទីក្រុងឲ្យបានបានឆាប់នៅក្នុងរយៈពេលដ៏ខ្លីដែលជាអង្គការដឹកនាំស្វ័យភាពទុកដូចជា របបសម្ព័ន្ធនយោបាយរដ្ឋថ្នាក់ក្រោមរបស់ប្រទេសជាតិ។ ក្នុងតួនាទីរបស់ពួកគេត្រូវបំពេញការងារប្រកបដោយប្រសិទ្ធិភាព នូវរាល់សេចក្តីសម្រេចចិត្តនៅគ្រប់ជាន់ថ្នាក់ ដែលមានអនុម័តដោយស្ថាបន័ដឹកនាំ ។ ដោយស្របទៅនឹងច្បាប់រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

ស្ថាបន័អំណាចមូលដ្ឋាន ឬគណៈកម្មាធិការប្រជាជនបដិវត្តន៍មូលដ្ឋាន(ជំពូក៧)បានចែងនៅក្នុងមាត្រាទី ២ ដូចខាងក្រោម ៖

- *គណៈកម្មាធិការបដិវត្តន៍ ត្រូវមាននៅគ្រប់ក្រុង គ្រប់សង្កាត់ គ្រប់ខេត្ត គ្រប់ឃុំ គ្រប់ស្រុក។*
- *សមាជិកគណៈកម្មាធិការប្រជាជនបដិវត្តន៍ឃុំ និងសង្កាត់ត្រូវបានប្រជាជននៅឃុំនិងសង្កាត់ជ្រើសរើសតាមគោលការណ៍បោះឆ្នោតជាសកលដោយស្មើភាពចំពោះមុខ និងតាមវិធីបោះឆ្នោតជ្រើសរើសជាសម្ងាត់ ។*
- *សមាជិកគណៈកម្មាធិការប្រជាជនបដិវត្តន៍ស្រុកត្រូវបានជ្រើសរើសដោយតំណាងគណៈកម្មាធិការប្រជាជនបដិវត្តន៍ ស្រុកតំណាងរណសិរ្សតំណាងអង្គការមហាជន ជាសមាជិករណសិរ្សថ្នាក់ខេត្ត ។*
- *សមាជិកនៃគណៈកម្មាធិការប្រជាជនបដិវត្តន៍ក្រុងត្រូវបានជ្រើសរើសដោយតំណាងគណៈកម្មាធិការប្រជាជនបដិវត្តន៍សង្កាត់ តំណាងរណសិរ្សនិងតំណាងអង្គការមហាជនជាសមាជិករណសិរ្សថ្នាក់ក្រុង ។*

ការវិភាគទៅលើឥរិយាបថរបស់អង្គការស្ថាបន័អំណាច***គណៈកម្មាធិការប្រជាជនបដិវត្តន៍*** ដែលធ្វើសកម្មភាពនៅក្នុងប្រទេសជាការចាំបាច់ ត្រូវតែចាប់អារម្មណ៍ទៅលើសារជាតុទាំងឡាយនៃការិយាល័យមជ្ឈិមនិយមមានដូចជា៖

- ការតែងតាំងអំណាចថ្នាក់ក្រោមដោយអំណាចថ្នាក់លើ
- សេចក្តីសម្រេចរបស់អំណាចថ្នាក់លើ គឺជាកាតព្វកិច្ចរបស់អំណាចថ្នាក់ក្រោម

- ពុំមានស្ថាបន័ណាមួយបង្ហាញជាក់លាក់ចំពោះការទទួលខុសត្រូវរបស់ខ្លួនចំពោះមុខប្រជាជន ។

ដូចនេះយើងឃើញថាការរៀបចំអំណាចនៅក្នុងប្រទេសកម្ពុជានៅពេលនោះមានលក្ខណៈប្រឆាំងនិងគោលការណ៍នៅក្នុងច្បាប់រដ្ឋធម្មនុញ្ញដែលបានចែងថា *គណៈកម្មាធិការប្រជាជនបដិវត្តន៍គ្រប់ថ្នាក់ទទួលខុសត្រូវចំពោះប្រជាជននៅមូលដ្ឋាន និងទទួលខុសត្រូវចំពោះអង្គការ រដ្ឋអំណាចថ្នាក់លើ(មាត្រា៧៤)* ។

**ដំណើរការពិភាក្សាលើសេចក្តីព្រាងច្បាប់រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ៖**

ការកែលំអរធ្វើឡើងសឹងតែគ្រប់ជំពូក តែការកែលំអរគម្រោងរដ្ឋធម្មនុញ្ញដែលនិយាយពីនយោបាយមានពេញនៅក្នុងទី ១ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៅកក្នុងប្រទេសកម្ពុជាដែលនិយាយជាអាទិ៍ថា *រដ្ឋមានភារកិច្ចការពារឯករាជ្យមាតុប្រទេសសេរីភាពរបស់ប្រជាជន សម្មទ្ធិផលរបស់បដិវត្តន៍ ស្តារនិងពង្រីកផលិតកម្ម ពង្រីកវប្បធម៌ យកចិត្តទុកដាក់ដោះស្រាយនិងលើកតំកើងជីវភាពរស់នៅរបស់ប្រជាជនទាំងខាងសម្ភារៈ និងទាំងខាងស្មារតី* (មាត្រា២កថាខណ្ឌ៣) ។ បើយើងប្រៀបធៀបទៅនិងសេចក្តីព្រាងរដ្ឋធម្មនុញ្ញ ដែលនិយាយអំពីកម្មវិធី *កសាងសម្មទ្ធិផលសង្គមនិយមមួយពិតប្រាកដ* ជាមួយនិងអត្ថបទរដ្ឋធម្មនុញ្ញដែលមានខ្លឹមសារ.......ឈានជំហានៗ ឆ្ពោះឡើងលទ្ធិសង្គមនិយម (មាត្រា១កថាខណ្ឌ២) ។

កំណែរសេចក្តីព្រាងរដ្ឋធម្មនុញ្ញនៅក្នុងជំពូកទី១ បានបញ្ជាក់ថា "*សាធារណរដ្ឋប្រជាមានិតកម្ពុជា ដឹកនាំដោយវណ្ណៈកម្មករសម្ពន្ធ័ភាពជាមួយនិងកសិករ បញ្ញវន្ត័ស្នេហាជាតិ និងស្រទាប់ប្រជាជនដែលធ្លាប់មានប្រពៃណីនៃការតស៊ូបដិវត្តន៍ប្រឆាំងនិងរបបសក្តិភូមិ របបអាណានិគមន៍និយម របបសក្រពត្តិនិយម ប្រតិកិរិយា នៅក្នុងការការពាឯករាជ្យ និងសន្តិភាពនៅក្នុងប្រទេសដើម្បីសុភមង្គលប្រជាជន*"។បន្ទាប់ពីមានការពិភាក្សាយ៉ាងតឹងតែងមកត្រូវបានជំនួសវិញដោយប្រជាជនកម្ពុជាជាម្ចាស់វាសនានៃប្រទេសរបស់ខ្លួន ។ អំណាចទាំងអស់របស់ប្រជាជន(មាត្រា២កថាខណ្ឌ១) ។ តាមពិតនៅក្នុងជីវិតជាក់ស្តែងអំណាចនយោបាយនៅក្នុងប្រទេសកម្ពុជាមិនមែនជារបស់ប្រជាជននោះទេ ពីព្រោះអំណាចនេះ ពុំបានឆ្លងកាត់ប្រជាជនឡើយ គឺឆ្លងកាត់ស្រទាប់អ្នកដឹកនាំ ដែលភាគច្រើនជាសមាជិកបក្សប្រជាជនបដិវត្តន៍កម្ពុជា ។

នៅក្នុងរដ្ឋធម្មនុញ្ញបើយើងប្រៀបធៀបទៅនិងសេចក្តីព្រាង យើងមើលឃើញថា បានពង្រីកជំពូកដែលជាប់ទាក់ទងទៅនិងនយោបាយរដ្ឋនៅក្នុងទំនាក់ទំនងជាមួយនិងជនជាតិភាគតិច ។ នៅក្នុងសេចក្តីព្រាងបាននិយាយថា ប្រជាជនដែលរស់នៅលើទឹកដីកម្ពុជា មានសិទ្ធិសិក្សាភាសាកំណើត និងគោរពប្រពៃណីទំនៀមទំលាប់របស់ខ្លួន ។

រីឯនៅក្នុងរដ្ឋធម្មនុញ្ញវិញ បានព្រមព្រៀងដូចតទៅ ៖ រដ្ឋអនុវត្តន៍នយោបាយសាមគ្គីភាព និងស្មើភាពរវាងប្រជាជាតិទាំងអស់ ដែលរស់នៅក្នុងសហគមន៍ជាតិកម្ពុជា ។ កំណែសេចក្ដីព្រាងរដ្ឋធម្មនុញ្ញ ត្រង់ចំណុចដ៏សំខាន់មួយទាក់ទងនិងសេដ្ឋកិច្ចសង្គម នៅក្នុងនោះបាននិយាយថា សេដ្ឋកិច្ចកម្ពុជាបានកសាងឡើង ដោយឈរលើទ្រង់ទ្រាយកម្មសិទ្ធិមហាជន នៅក្នុងបែបផែនផលិតកម្ម ។ ប៉ុន្តែ គេបានធ្វើកំណែរទម្រង់លើសេចក្ដីព្រាងដោយអនុមត័យកកម្មសិទ្ធិ ៣ យ៉ាង គឺ កម្មសិទ្ធិរដ្ឋ កម្មសិទ្ធិសមូហភាព(កម្មសិទ្ធិរបស់ក្រុមពលកររួមគ្នា) និងកម្មសិទ្ធិគ្រួសារ ។ នៅក្នុងចំណុចនេះរដ្ឋធម្មនុញ្ញបានចែងថារដ្ឋយកចិត្តទុកដាក់ពង្រីកផលិតកម្មរបស់ប្រើប្រាស់ពាណិជ្ជកម្ម គមនាគមន៍ និងការដឹកជញ្ជូន រដ្ឋជួយទំនុកបំរុង និងពង្រីកសិប្បកម្ម ឧស្សាហកម្មតូចៗ (មាត្រា១៣) ។ ហេតុដូចនេះហើយ រដ្ឋធម្មនុញ្ញកម្ពុជាត្រូវបានអនុមត័ជាឯកច្ឆ័ននៅក្នុងសម័យប្រជុំលើកទី១នីតិកាលទី១ នៃរដ្ឋសភាជាតិ នាថ្ងៃទី ២៥ មិថុនា ១៩៨១ ហើយបានប្រកាស់ឲ្យប្រើប្រាស់ចាប់ពីថ្ងៃទី ២៧ មិថុនា ១៩៨១ ។

នៅក្នុងសម័យនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាមានអង្គការគ្រប់គ្រងរដ្ឋសំខាន់ៗចំនួន ៤ គឺ ៖

- *គណបក្សប្រជាជនបដិវត្តន៍កម្ពុជាដែលដឹកនាំដោយអគ្គលេខាធិការលោក ប៉ែន សុវណ្ណ(អតីតខ្មែរឥស្សរៈ ) ដែលបានរៀនសូត្រ នៅប្រទេសវៀតណាមខាងជើង ឆ្នាំ១៩៥៤ ។ ប៉ុន្តែត្រូវប្ដូរមកលោក ហេង សំរិន វិញនៅខែធ្នូ ឆ្នាំ១៩៨១ ដែលគណបក្សនេះមានការិយាល័យ នៅគ្រប់ខេត្ត/ក្រុង រីឯការជ្រើសសរើសឲ្យចូលបក្ស ឬក្រុមស្នូលត្រូវបានត្រួតពិនិត្យយ៉ាងម៉ត់ចត់ពិសេសលើប្រវត្តិរូប ហើយមានការតាមដានជាច្រើនខែ ។*
- *ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ ឬក្រុមប្រឹក្សារដ្ឋមន្ត្រី មានសមាជិក១៧រូប ប្រធានលោក ប៉ែន សុវណ្ណ តែត្រូវប្ដូរមកឱ្យលោក ចាន់ស៊ី នៅឆ្នាំ១៩៨១ ទិសដៅរបស់ក្រុមប្រឹក្សានេះគឺសម្រេចទិសដៅសំខាន់ៗរបស់បក្ស ហើយការប្រជុំត្រូវបានធ្វើយ៉ាងទៀងទាត់ ដើម្បីចាត់វិធានការរដ្ឋបានច្បាស់លាស់ សម្រាប់រដ្ឋមន្ត្រីយកទៅផ្សព្វផ្សាយតាមក្រសួង មន្ទីរ កុំឲ្យខុសទិសដៅ ។ នៅពេលពេលប្រជុំ តំណាងក្រសួងនីមួយៗមករាយការណ៍ពីការសម្រេចបាននិងបញ្ហាដែលកើតមាន ។ ដែលមានក្រសួង កសិកម្ម អប់រំ ការបរទេស សុខាភិបាល វប្បធម៌ និងព័ត៌មាន ។ ឬក្រសួងផែនការទើបបង្កើតនៅឆ្នាំ១៩៨១ ដើម្បីរៀបចំគំរោងផែនការស្ដារជាតិ ។*
- *ក្រុមប្រឹក្សារដ្ឋ មានលោកហេង សំរិន ជាប្រធាន ហើយអង្គភាពនេះមានតួនាទីលើបញ្ហាច្បាប់ របស់រដ្ឋ រៀបចំ ក្រមព្រហ្មទណ្ឌ និងកែប្រែទោសប្រហារជីវិត ។*

- *រដ្ឋសភាជាតិមានសមាជិក១១៧រូបដែលកើតពីការបោះឆ្នោតខែឧសភា ១៩៨១ ហើយការប្រជុំលើកទី១នៅខែមិថុនា១៩៨១បានជ្រើសរើសប្រធានគណៈរដ្ឋមន្ត្រីនិង ក្រុមប្រឹក្សារដ្ឋ។ការបើកសម័យប្រជុំវិសាម័ញ្ញមួយកាលពីថ្ងៃទី ២៩-៣០ មេសា ១៩៨៩ បានប្តូរឈ្មោះពីសាធារណរដ្ឋកម្ពុជា មកជា រដ្ឋកម្ពុជា វិញ ព្រមទាំងប្តូរ ទង់ជាតិ ភ្លេងជាតិ ។ ហើយបានលាប់បំបាត់ចោលនូវ ទោសប្រហារជីវិតនិងយក សាសនាព្រះពុទ្ធជាសាសនារដ្ឋ ច្បាប់កម្មសិទ្ធិឯកជន និងទីផ្សារសេរីត្រូវបានបង្កើត ឡើង ។ ហើយរដ្ឋធម្មនុញ្ញចែងថា ប្រទេសកម្ពុជាជាប្រទេស បានបន្ទូរបន្ថយ ព្រមធ្វើ ការចរចាជាមួយបក្ស ប្រឆាំង ទាំង៣ ដែលកំពុងតស៊ូនៅតាមព្រំដែន ខ្មែរ-ថៃ ។*

## ៣.២ សាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងស្ថានភាពសង្គ្រាម

### ក. ការបង្កើតសម្ពន្ធ័ភាព សីហនុ សឺន សាន ខ្មែរក្រហមប្រឆាំងនិងកងទព័វៀតណាម និង សាធារណរដ្ឋប្រជាមានិតកម្ពុជា

ក្រោយថ្ងៃ ៧ មករា ១៩៧៩ របបកម្ពុជាប្រជាធិបតេយ្យបានដួលរលំទាំងស្រុង ហើយត្រូវ បោសសម្អាតដោយកងទព័វៀតណាម និងរណសិរ្យសង្គ្រោះជាតិកម្ពុជា ។ ប៉ុល ពត បានបញ្ជូន អៀង សារី ទៅទីក្រុងប៉េកាំង ដើម្បីជួបចរចារជាមួយលោក តេង ស៊ាវពីង លោក ហ៊្វ ហ្គោផេង និងមេដឹកនាំចិនផ្សេងៗទៀត ។ លោក តេង ស៊ាវពីង បានផ្តល់ដំបុន្មានដល់ អៀង សារី ថាខ្លួន គួរតែកែប្រែរចនាសម្ពន្ធ័ដឹកនាំថ្មីបង្កើតគោលនយោបាយថ្មី ដើម្បីស្វែងរកប្រជាប្រិយភាព ។ លោកបានបន្តទៀតថា នៅទីក្រុងប៉ារីសមានអង្គការមួយសែលមានឈ្មោះថា រដ្ឋាភិបាលរំដោះ កម្ពុជា ។គេបានបោះពុម្ពសេចក្តីប្រកាស៥ ចំណុចដែល ៤ចំណុចជាចំនុចល្អនិង ១ចំណុច ទៀតជាចំណុចអាក្រក់ដោយសារគេទាំងអស់គ្នាប្រឆាំងនិងប៉ុល ពតដែលគេហៅថារបបផ្តាច់ ការ។អង្គការនេះមានមនុស្សរបស់គេនៅសហរដ្ឋអាមេរិចនិងនៅប្រទេសដ៏ទៃទៀតដូចជាថៃ …។ ក្នុងន័យនេះលោក តេង ស៊ាវពីង ចង់បញ្ជាក់ការបង្ហាញមុខរបស់ ប៉ុល ពត នៅលើឆាក អន្តរជាតិមិនសូវជាល្អទេ មិនចង់ឲ្យ ប៉ុល ពត លាលែងពីតំណែងដោយប្រគល់តំណែងឲ្យទៅ ខៀវ សំផន (ការលាលែងពីតំណែងនេះគ្រាន់តែជារូបភាពបំភ័ន្តភ្នែកប៉ុណ្ណោះ ប៉ុល ពត នៅតែ មានអំណាចដដែល) និងសហាការជាមួយ សម្តេច នរោត្តម សីហនុក៏ដូចជាក្រុមប្រឆាំងវៀត ណាមទាំងអស់ ហើយតែងតាំងសម្តេច សីហនុ ជាប្រធានបក្សដើម្បីស្វែងរកប្រជាប្រិយភាព ។ ចិន បានប្រគល់ប្រាក់ចំនួន ៥លានដុល្លារ ដល់អៀង សារី សម្រាប់ធ្វើការតស៊ូព្រមទាំងនិយាយ ជាមួយសម្តេច សីហនុ ដើម្បីឲ្យព្រះអង្គសហាការជាមួយ ប៉ុល ពត ។ ព្រះអង្គមិនត្រឹមតែមិន សហាការជាមួយ ប៉ុល ពត ប៉ុណ្ណោះទេ ព្រះអង្គបែរជាប្រមែរប្រមូលភាគីទ្រង់បង្កើតចលនា

សហាពន្ធ័ ខ្មែរអ្នកជាតិនិយមនៅរដូវស្លឹកឈើជ្រុះនៅឆ្នាំ១៩៧៩ ហើយបានឲ្យយោបល់ទៅសហាពន្ធ័ដើម្បីធ្វើការចរចារជាមួយវៀតណាមស្ដីអំពីការបង្កើតកម្ពុជាឯករាជ្យអព្យាក្រឹត្យ។ សម្ដេច នរោត្ដម សីហនុ បានសរសេរសំបុត្រផ្ញើរទៅមិត្តភក្តិរបស់ទ្រង់ គឺនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ថាម វ៉ាន់ដុង ចំនួន ៣ លើកប៉ុន្ដែពុំបានឃើញចម្លើយមកវិញទាល់តែសោះ ។ ដោយសារតែយល់ឃើញពីចំណងមិត្តភាពដ៏យូរខែ យូរឆ្នាំ ព្រះអង្គបានរងចាំ ។ ដោយសារស្ថានការណ៍នៅលើឆាកអន្តរជាតិកំពុងតែកើនឡើងដោយការចោទប្រកាន់អំពីបទនយោបាយឈ្លានពានកម្ពុជា ពេលនោះអ្នកកាន់អំណាចហាណូយបានឆ្លើយតបសំបុត្រមកវិញជាមួយនិងសំណើរសុំឲ្យទ្រង់កាន់តំណែងជាមេដឹកនាំរដ្ឋ ។ នៅខែមេសា ឆ្នាំ១៩៨០ សម្ដេច នរោត្ដម សីហនុ បានធ្វើសេចក្ដីប្រកាសអំពីការត្រៀមខ្លួនរបស់ព្រអង្គ ធ្វើសំណើរទៅកាន់សាធារណរដ្ឋប្រជាមានិតកម្ពុជា ក្នុងនាមជាពលរដ្ឋសាមញ្ញម្នាក់ ។ ប៉ុន្ដែជាការឆ្លើយតបមកវិញ ចំពោះកាយវិការយ៉ាងសាមញ្ញបែបនេះទ្រង់ពុំបានទទួលទាំងខាងភ្នំពេញ និងទាំងខាងហាណូយ ។ សេចក្ដីសម្រេចរបស់ព្រះអង្គបានលេចឡើងនៅខែ ឧសភា ១៩៨១ នៅពេលដែលព្រះអង្គបង្កើតរណសិរ្សឯកភាពជាតិ ដើម្បីអធិបតេយ្យភាព ឯករាជ្យភាព អព្យាក្រឹត្យភាព សន្តិភាពនិងកិច្ចសហប្រតិបត្តិការកម្ពុជា ( FUNCINPEC) ។ ចំណែកចលនាតស៊ូមួយទៀតក៏បានកើតឡើងដែរដែលមានឈ្មោះថា ប៉ូលីណាកា ជាចលនាតស៊ូ សីហនុនិយម ដែលបានបង្កើតឡើងនៅឆ្នាំ ១៩៧៩ ។ ទីបំផុតក្រោមគំនាបពី វ៉ាស៊ីនតោន ប៉េកាំង និងសមាជិកអាស៊ាន នៅថ្ងៃទី ២២ មិថុនា ១៩៨២ បក្សតស៊ូទាំង ៣ ភាគី( សីហនុ សឺន សាន ខ្មែរក្រហម ) បានចុះហត្ថលេខាព្រមព្រៀងគ្នា ដើម្បីរដ្ឋាភិបាលត្រីភាគីនៅកូឡាឡាំពួដោយប៉ូលីណាកា មានកងទ័ពប្រមាណ ៣០០០ នាក់ **រជរបខ** មានប្រមាណ ៨០០០ នាក់ និងខ្មែរក្រហមមានប្រមាណ ៣៥០០ នាក់ ដែលមានឈ្មោះថារដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ រដ្ឋាភិបាលត្រីភាគីមានទិសដៅនយោបាយ ២ ដ៏សំខាន់សម្រាប់តស៊ូរបស់ពួកគេគឺផ្ដួលរំលំសាធារណរដ្ឋប្រជាមានិតកម្ពុជា និងបង្ខំវៀតណាមឲ្យដកទ័ពចេញពីកម្ពុជា ដើម្បីសម្រេចទិសដៅនេះគេបានប្រកាសដាក់ចេញនូវគម្រោងលើទិសដៅ ៣ សំខាន់៖

1. ការតស៊ូដោយអាវុធ និងបង្កើតតំបន់រំដោះចេញការគ្រប់គ្រងពួកខ្មាំងឈ្លានពាន
2. ការតស៊ូដើម្បីប្រជាប្រិយភាពក្នុងជួរប្រជាជនខ្មែរទាំងមូល បំផុសចលនាតស៊ូប្រឆាំងនិងនយោបាយអាយ៉ងយួន
3. សកម្មភាពការទូតដើម្បីជម្រុញឲ្យមានការហ៊ុមពន្ធ័សាធារណរដ្ឋប្រជាមានិតកម្ពុជានៅលើឆាកអន្តរជាតិ ។

**ខ. សភាពការណ៍សឹកនៅក្នុងប្រទេស**

ការដាក់ទិសដៅដ៏សំខសាន់ជាដំបូងរបស់ខ្មែរប្រឆាំងការធ្វសកម្មភាពនៅលើទឹក ដីកម្ពុជាដើម្បីផ្តួលរំលំអំណាចសាធារណរដ្ឋប្រជាមានិតកម្ពុជាដោយកម្លាំងអាវុធ។ ប្រតិបត្តិការទ្រង់ទ្រាយធំប្រឆាំងនិងមូលដ្ឋាន និងជំរុំមួយចំនួនទៀតត្រូវវាយកំទេចនៅក្នុងរដូវប្រាំងឆ្នាំ ១៩៨៤ដល់១៩៨៥ ។ ប្រតិបត្តិការទី ១ មានទិសដៅប្រឆាំងនិងក្រុមខ្មែរក្រហមដែលមានចំនួនច្រើនជាងគេ ។ ប្រតិបត្តិការនេះទទួលបានភាពជោគជ័យដោយបានកម្ទេចតំបន់កាន់កាប់ខេត្តបាត់ដំបង ជួរភ្នំស្នឹង និងមូលដ្ឋានដ៏មាំពីរទៀតក្នុងខេត្តសៀមរាបក៏ត្រូវបានកម្ទេចដែរ ។ នៅឆ្នាំ ១៩៨៣ ទ័ពជាង ៤០០០ នាក់របស់ សឺន សាន នៅខេត្តពោធិ៍សាត់បានរត់ខ្ចាត់ខ្ចាយ ។ ជោគជ័យដ៏ធំមួយទៀត គឺការវាយកម្ទេចទីតាំងបញ្ជាការដ្ឋាន ប៉ុល ពត នៅខេត្តព្រះវិហារ ។ ជំហានទី ២ គឺមុខសញ្ញាកម្ទេចទីតាំងរបស់កងកម្លាំង សឺន សាន ។ នៅខែ មករា ឆ្នាំ១៩៨៥កងកម្លាំងរបស់ សឺន សានត្រូវបានដៅលរលំនៅក្នុងជំរុំធំៗដូចជាជំរុំប្ញទ្ធិសែន អូរបុក ណងសាមេត ហើយជំរុំអំពិលដែលជាបញ្ជាការដ្ឋានរបស់ សឺន សានក៏ត្រូវដួលរលំដែរ ។

លទ្ធផលរួមនៃប្រតិបត្តិការ ឆ្នាំ ១៩៨៣ ដល់ ១៩៨៥ ជំរុំនិងមូលដ្ឋានទព័របស់សម្ពន្ធ័ត្រីភាគីកម្ពុជាប្រជាធិបតេយ្យ ដែលស្ថិតនៅតាមបណ្តោយព្រំដែន កម្ពុជាត្រូវបានកម្ទេចទាំងស្រុង ។ ជ័យជំនះនេះមានន័យធំធេងណាស់សម្រាប់ជោគវាសនានៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ការពិតអំណាចភ្នំពេញបានទទួលឱកាសដើម្បីពង្រីកកម្លាំងនិងប្រពន្ធ័គ្រប់នៅលើតំបន់ជាច្រើនថែមទៀតនៅក្នុងប្រទេសកម្ពុជា ។

ដំណាក់កាលប្រយុទ្ធគ្នាជាទ្រង់ទ្រាយធំសារជាថ្មីបានចាប់ផ្តើមនៅចុងឆ្នាំ១៩៨ដោយសារការដកទព័របស់វៀតណាម ចេញពីទឹកដីកម្ពុជាដែលជាកម្លាំងដ៏សំខាន់ក្នុងការវាយបង្ក្រាបទៅលើកងទព័រដ្ឋាភិបាលត្រីភាគី ។ ដោយសារពួកខ្មែរប្រឆាំងគិតថាកម្លាំងទ័ពរដ្ឋាភិបាលភ្នំពេញមានលទ្ធភាពនិងសមត្ថភាពទាបជាងកម្លាំងទ័ពវៀតណាម ពួកត្រីភាគីសង្ឃឹមថានិងដណ្តើមអំណាចពីរដ្ឋាភិបាលក្រុងភ្នំពេញវិញដោយអាវុធ ។ក្រុមខ្មែរប្រឆាំងបានចូលកាន់កាប់ភូមិករប្រជាជនខ្មែរ ជាពិសេសតំបន់ជុំវិញបឹងទន្លេសាប និងខេត្តបាត់ដំបង ការប្រយុទ្ធតទល់គ្នាក៏កើតឡើងនៅខេត្តពោធិ៍សាត់ កំពង់ឆ្នាំង គំពង់ធំ និងបាត់ដំបង ។

សង្គ្រាមគ្មានថ្ងៃបញ្ចប់ដែលពាក់ពន្ធ័និងចិន និងសហរដ្ឋអាមេរិចក្នុងការជួយខ្មែរប្រឆាំងបានធ្វើឲ្យប្រទេសវៀតណាម កម្ពុជាខ្សោះសឹងតែអស់ធនធានរលីង ប្រជាជនភាគច្រើនរស់នៅក្នុងភាពទុរគត សេដ្ឋកិច្ចកម្ពុយជានិងវៀតណាមវិវត្តយឺតណាស់បើព្រៀបធៀបទៅនឹងបណ្តាលប្រទេសនៅក្នុងតំបន់-សមាជិកអាស៊ាន ។ ទីបំផុតសភាពការនៅប្រទេសវៀតណាមបានធ្វើអោយមេដឹកនាំវៀតណាមធ្វើការសន្និដ្ឋានថា ចាំបាច់ត្រូវកែប្រែឥរិយាបថ ជាមួយនឹងកម្ពុជា

ហើយជ្រើសរើសយកមាគ៌ានយោបាយសម្រុះសម្រួលដោយឈរលើគោលការណ៍យោគយល់គ្នាជាមូលដ្ឋានមិនរឹងត្អឹងទៅលើមនោគមវិជ្ជានយោបាយ ។

**គ. ផែនការ"ក-៥"**

សាធារណរដ្ឋប្រជាមានិតកម្ពុជាបានប្រកាសជ័យជំនះរបស់ទ័ពវៀតណាមនិងទ័ពកម្ពុជានៅក្នុងខែធ្នូឆ្នាំ១៩៨ ឧត្តមសេនីយ៍ឡេឌឹកអាញ់(Le DucAnh)ដែលជាអ្នកចូលរួមចំណែកយ៉ាងសំខាន់មួយក្នុងការវាយលុកក្នុងឆ្នាំ១៩៧៨និងជាមេបញ្ជាការកងទ័ពសាធារណរដ្ឋសង្គមនិយមវៀតណាមនៅក្នុងប្រទេសកម្ពុជាបានបង្ហាញនូវចំណុចគន្លឹះចំនួន៥ដែលបង្កើតបានជាយុទ្ធ-សាស្ត្រសម្រាប់កម្លាំងយោធាវៀតណាមដើម្បីធ្វើការការពារ និងប្រមូលកម្លាំងបដិវត្តន៍កម្ពុជា÷

*១.ឥណ្ឌូចិនគឺជារោងល្ខោនទោលមួយនៃប្រតិបត្តិការ ដូច្នេះការគម្រាមកំហែងណាមួយចំពោះឯករាជ្យនៃប្រទេសណាមួយនៅចំណោមប្រទេសទាំង៣គឺជាការគម្រាមកំហែងចំពោះឯករាជ្យទាំង៣ប្រទេស។*

*២.ជោគជ័យបដិវត្តន៍កម្ពុជា ត្រូវបានសម្រេចដោយប្រជាជនកម្ពុជាខ្លួនឯងផ្ទាល់។*

*៣.ប្រជាជនតាមមូលដ្ឋាន ត្រូវបានកេណ្ឌជាកម្លាំងទ័ពដើម្បីពង្រីកការការពារជាតិ។*

*៤ .ជម្លោះចេញមកពីសមរភូមិពីគឺ ពីរព្រំដែនកម្ពុជា-ថៃ និងពីផ្ទៃក្នុងប្រទេស។*

*ការបង្កើតកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាគឺតម្រូវការយុទ្ធសាស្ត្រចាំបាច់ និងបន្ទាន់"នៃបដិវត្តន៍កម្ពុជា"* ***ការងារបន្ទាន់នៃការប្រមូលផ្តុំរចនាសម្ព័ន្ធ ជាបង្គោលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាតម្រូវការចាំបាច់សម្រាប់ជាដំណោះស្រាយដើម្បីធ្វើការលិបបំបាត់ចលនាប្រឆាំងនឹងការដាក់បញ្ចូលកម្ពុជានៅក្នុងប្លុកសង្គមនិយមឥណ្ឌូចិន។***

ប៉ុបន្តែសម្តេចហ៊ុនសែនបានអះអាងថាគាត់មិនមែនជាប្រធាននៃគណៈកម្មាធិការនេះ *"ក៥" ផែនការបានលេចឡើងតាំងពីឆ្នាំ១៩៨៤មុនពេលដែលខ្ញុំក្លាយជានាយករដ្ឋមន្ត្រី។"ក៥"ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងការពារជាតិ។ទំនួលខុសត្រូវត្រូវបានចែករំលែកឲអាជ្ញាធរតាមបណ្តាខេត្ត តាមកងពលយោធានៅតំបន់នោះ។ ការជ្រើសរើសកម្លាំងទ័ពថ្មីឬការបញ្ជូនប្រជាជនអោយចូលរួមក្នុងផែនការនេះ ត្រូវតែកំណត់ដោយអនុក្រឹត្យឬការសម្រេចចិត្តរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។* ប៉ុន្តែតាំងពីឆ្នាំ ១៩៨៥ទើបកម្មវិធី "ក៥" បានចាប់ផ្តើមអនុវត្តន៍ ស្របពេលគ្នានឹងការផ្តាច់ជ្វាចិត្តរបស់កងកម្លាំទ័ពព្រៃប្រកាសពួកគេននិងបើកការវាយប្រហារទ្រង់ទ្រាយធំ ផ្តផ្តាច់ជីវិតជាមួយរដ្ឋាភិបាលភ្នំពេញ និងកងទព័វៀតណាម ។ តែតាមពិតនៅរដូវប្រាំងឆ្នាំ ១៩៨៤ដល់១៩៨៥ នោះហើយដែលកងតស៊ូនឹងជំរុំជនភៀសខ្លួននៅជាយដែនកម្ពុជា-ថៃ ត្រូវកងទ័ពវៀតណាម វាយកំទិចចោលអស់ទាំងកងកម្លាំងតស៊ូផង ក៏ត្រុវរងការខូចខាត

យ៉ាងដំណំ ។ យើងជរុំភៀសខ្លួន ត្រូវរុះរើទីតាំង ដកថយទៅបោះនៅកន្លែងថ្មីដែលភាគច្រើននៅលើទឹកដីថៃ ។

នៅថ្ងៃទី០៣ តុលា ១៩៨៣ រដ្ឋាភិបាលបានកំណត់កាតព្វកិច្ចយោធារយៈពេល៥ឆ្នាំសំរាប់ពលរដ្ឋរបស់ប្រុសស្រីម្នាក់ៗចាប់ពីអាយុ១៨ឆ្នាំឡើងទៅ ។ ក្នុងនៅហាដែលក៏បានកំណត់កាតាព្វកិច្ច យោធាសំរាប់យុវជននិងយុវនារីដែលមានអាយុចាប់ពី១៨ឆ្នាំឡើងដែល ដើម្បីជំរុញការអនុវត្តផែនការ "ក៥" ដែលជាផែនការកាប់ឆ្ការព្រៃក្នុងទ្រង់ទ្រាយធំរបស់រដ្ឋាភិបាលនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ដើម្បីផលប្រយោជន៍ដែលហៅថា "បំផ្លាញជំរកខ្មាំង" នៅតាមព្រំដែននឹងនៅតាមដំបន់ជនបទ ។ ដូច្នេះព្រៃឈើត្រូវបានរងការបំផ្លាញយ៉ាងតំណំ ។

មានរឿងសោកនាដកម្មជាច្រើនទាក់ទងនិងការបំពេញកាតព្វកិច្ច **ក៥** របស់ប្រជាជនខ្មែរ។ ដោយសារការប្រឈមមុខនិងសេចក្តីស្លាប់ដោយគ្រាប់ផ្លោងរបស់ចលនាតស៊ូ ការវាយប្រហារត្រង់ៗ ការដើរជាន់មីន និងជម្ងឺផ្សេងៗ ជាពិសេសគ្រុនចាញ់ ទើបប្រជាជនខ្មែរភាគច្រើនតែងតែប៉ុនប៉ងគេចវេសពីការបំពេញកាតព្វកិច្ចនេះ ។ អ្នកខ្លះមានលុយកាក់ច្រើនក៏ជូលឲ្យអ្នកដ៏ទៃទៅជំនួស អ្នកខ្លះទៀតក៏សូកមន្ត្រីមូលដ្ឋានពីការចុចឈ្មោះឲ្យទៅ ។ ហេតុនេះហើយបានជាតារាកំប្លែង ព្រំ ម៉ាញ ធ្លាប់និយាយលេងទាក់ទងនិងបញ្ហានេះថា *ពលករស្ម័គ្រចិត្ត រុញក្តិតឡើងឡាន ទៅអាចជិះឡាន មកវិញជិះចាន ទទូរសំពត់ស* ។

*ក៥" ជា អក្សរកាត់ចេញពីប្រយោគថា "កែន កងកម្លាំង កាប់ឆ្ការព្រៃ ការពារព្រុំដែន កម្ពុជា"។*

## ៣.៣ដំណើរវិវត្តន៍សេដ្ឋកច្ចរដ្ឋដំណាក់កាលសាធារណរដ្ឋប្រជាមានិតកម្ពុជា

សេដ្ឋកិច្ចរដ្ឋពឹងផ្អែកលើវិស័យកសិកម្មបែបយថា ផល ប្រជាជន ៩០%ជាកសិករប្រកបរបរធ្វើស្រែចម្ការ ពិសេសដំណាំស្រូវ ។ ឆ្នាំ១៩៨៨ ផលស្រូវ មាន២.៧០០.០០០តោន ហើយកើនដល់៣.០០០.០០០តោននៅឆ្នាំ ១៩៩០ ។មហាសន្និបាតបក្សលើកទី៥បានចាត់វិធានការ បីយ៉ាងដើម្បីផលិតស្បៀងគឺពង្រីលដីកសិកម្មបង្កើតរដូវដាំដុះ និងប្រពលវប្បកម្ម ។ ដំណាំកៅស៊ូជាផលិតផលនាំចេញសំខាន់របស់រដ្ឋ ដែលរដ្ឋបានស្តារឡើងនិងដាំឡើងវិញនូវចម្ការកៅស៊ូចាប់ពីឆ្នាំ១៩៨៥ ដែលចម្ការទាំងនោះមាននៅកំពង់ចាម ក្រចេះ រតនគីរី កំពង់សោម ។ រីឯអាជីវកម្មឈើក៏មានការរីកចម្រើនខ្លាំងណាស់ដែររហូតក្លាយជាមុខព្រួញសំខាន់នៃសេដ្ឋកិច្ចជាតិ។ ហើយការនេសាទ ទាំងទឹកប្រៃ និងទឹកសាប បានទទួលជោគជ័យខ្លាំងណាស់ដែរវាបានជួយសម្រួលដល់ជិវិភាពប្រជាជន សេដ្ឋកិច្ច និងសំរាប់នាំចេញទៅក្រៅប្រទេស ។

សាធារណរដ្ឋប្រជាមានិតកម្ពុជា មានគោលដៅក្នុងការកសាងប្រទេសជាតិជាជំហានៗឆ្លងកាត់អន្តរកាលឆ្ពោះទៅរកលទ្ធិសង្គមនិយម ។ របបនេះមានគោលដៅកសាងប្រទេសជាតិដោយគេចង់សម្រេចបានត្រឹមតែជា"ប្រទេសសង្គមនិយម" ប៉ុណ្ណោះមិនមានគោលនយោបាយ

កសាងតាមរបៀប"មហាលោតផ្លោះ មហាអស្ចារ្យ" ដូចរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ។ យឿនសេដ្ឋកិច្ចរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាជាសេដ្ឋកិច្ចសង្គមនិយម នៅដើមរបប នេះ ដើម្បីដោះស្រាយបញ្ហាខ្វះខាតកម្លាំងមនុស្សប្រុស សត្វពាហនសំរាប់អូសទាញ នឹង មធ្យោបាយផលិតកម្មកសិកម្មរដ្ឋាភិបាលរៀបចំអោយមាន "ក្រុមសាមគ្គីបង្កបង្កើនផល" តែមិន មែន "ដាក់កម្មសិទ្ធិរួម ហូបរួម" នោះទេ ។ ប៉ុន្តែផលស្រូវទាំនោះមិនមានបរិមាណច្រើនអាចអោយគេរំលែកលក់ដូរដើម្បីយកប្រាក់ទិញម្ហូបអាហារប្រចាំថ្ងៃបានទេ កសិករត្រូវតែប្រកបមុខរបររួមផ្សំបន្ថែមទៀត ទើបអាចមានជីវភាពសមរម្យបាន ។ ក្រុមសមគ្គីបង្កបង្កើនផលត្រូវរំសាយនៅឆ្នាំ ១៩៨៣ បន្ទាប់ពីប្រមូលផលស្រូវដើមឆ្នាំរួម ហើយដីស្រែរបស់ក្រុមសាមគ្គីនីមួយៗ ត្រូវពុះចែកតាមគ្រួសារនីមួយៗ ជាសមាជិកក្រុមទៅតាមចំនួនសមាជិកពេញវ័យនៃគ្រួសារនីមួយៗ ។

ការលើកទិសដៅនយោបាយសេដ្ឋកិច្ចគឺស្របទៅតាមការសម្រេចចិត្តរបស់មហាសន្និបាទបក្សប្រជាជនបដិវត្តកម្ពុជា។ ជាក់ស្តែងមហាសន្និបាទលើកទី៤នៅឆ្នាំ១៩៨១នឹងមហាសន្និបាទបក្សទូទាំងប្រទេសនៅឆ្នាំ ១៩៨៥ បានកំណត់ទិសដៅសេដ្ឋកិច្ច ដោយពឹងផ្អែកលើមុខព្រួញសេដ្ឋកិច្ចបួនផ្នែកដូចគ្នាគឺ:

- ជំរុញអាជីវកម្មដំណាំស្បៀងក្នុងវិស័យកសិកម្ម
- ជំរុញការធ្វើអាជីវកម្មចាក់ជ័រកៅស៊ូ
- ជំរុញអាជីវកម្ម ឈើនិងរុក្ខាប្រមាញ់
- ជំរុញការបង្កើនទិន្នផលនេសាទត្រី ទាំងទឹកសាបនឹងទឹកប្រៃ ។

សង្គមកម្ពុជាបានធ្វើដំណើរបន្តិចម្តងៗ ទៅកាន់ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារដោយឆ្លងកាត់បីដំណាក់កាល:

1. "**ភ្ញាស់** " នៅពេលប្រព័ន្ធគ្មានទំនាក់ទំនងទីផ្សារ នៅមានរូបរាងខ្លាំងនូវឡើយរឹងទ្រង់ទ្រាយទីផ្សារ ទោះបីលេចឡើងហើយក៏ដោយ បន្តែក្នុងលក្ខណៈពាក់កណ្តាលស្របច្បាប់នូវឡើយ ។
2. "**លំនឹង**" ឬ"**យោគយល់**" នៅពេលដែលពួកអ្នកកាន់អំណាចរៀបចំគំរោងសកម្មភាពសង្គម មានលក្ខណៈយោគយល់ដោយក្នុងនោះទទួលស្គាល់នូវបង្រួបបង្រួមរវាងសេដ្ឋកិច្ចផែនការជាមួយនឹងការប្រកួតប្រជែងទីផ្សារ ។
3. "**ទីផ្សារសេរី**" នៅពេលដែលរចនាសម្ព័នទីផ្សារបានក្លាយទៅជាប្រព័ន្ធមួយគ្រប់គ្រងលើវិស័យសេដ្ឋកិច្ច ។ អាចលេចឡើងដូចជា បម្រែបម្រួលនៃរបបកុំម្មុយនីស្តដែរ នៅក្នុងដំណើរកំណែទម្រង់រចនាសម្ព័ន្ធនយោបាយ ។

- ប្រភពជោគជ័យក្នុងការចងក្រងសហគមន៍សមូលហភាពដំណាក់កាលទី២នេះ អាស្រ័យទៅនឹងកត្តា ៣ យ៉ាងគឺ:
  1. ក្នុងជួរកសិករនៅបន្សល់ទុកនូវ ស្ថានភាពភ័យខ្លាច តាំងពីរបបខ្មែរក្រហមមក ហើយពួកគេមានទំលាប់ត្រូវតែគោរពតាមទាំងអស់នូវរាល់បទបញ្ជារថ្នាក់ដឹកនាំបញ្ជូនមក ។
  2. នៅក្នុងដំណាក់កាលដ៏ធ្ងន់ធ្ងរ នៅក្នុងតំបន់ជនបទ ជាការពិតណាស់ប្រជាជនដោយបញ្ចេញលក្ខណះមួយជួយគ្នាទៅវិញទៅមក ។ នៅពេលនោះប្រជាជនបានជួយគ្នាមិនត្រឹមតែលើការផលិតស្រូវអង្ករនោះទេ ប៉ុន្តែពួកគេជួយគ្នានៅលើវិស័យផ្សេងៗទៀតដូចជា សង់ផ្ទះ គាំពារអ្នកជំងឺនឹងជនពិការ ។
  3. តំបន់ធ្វើស្រែចំការទាំងអស់នៅក្នុងប្រទេសដំណាក់កាលឆ្នាំ ១៩៧៩ ដល់ ១៩៨០ ទាមទារអោយមានការរៀបចំប្រព័ន្ធការងារឡើងវិញដោយសារនៅក្នុងដំណាក់កាលក្រោមការដឹកនាំរបស់ពួកខ្មែរក្រហមរចនាសម្ព័ននៅទីជនបទ ត្រូវបានផ្លាស់ប្តូរទាំងអស់ ។ ទន្ទឹមនឹងនេះដែរក៏ត្រូវការទាមទារអោយរៀបចំប្រព័ន្ធ ស្រោចស្រព ដែលបានខូចខាតនៅក្នុងដំណាក់កាលនៃការប៉ះទង្គិចគ្នាដោយអាវុធនៅតាមភូមិជនបទ ។

- គួរកត់សម្គាល់ថាក្រុមបង្កបង្កើនផលត្រូវបានបែងចែកជា ៣ ប្រភេទគឺ:

***ក្រុមសាមគ្គីបង្កបង្កើនផលប្រភេទទី៣:***រចនាសម្ព័នក្រុមសគ្គី-៣មានលក្ខណះខុសគ្នាច្រើនណាស់ទៅនឹងកុំម្មុយនីស្ត"សេដ្ឋកិច្ចថ្មី" ដែលជាទិសដៅរបស់ពួកកុំម្មុនីស្ត ។ ប៉ុន្តែផ្ទុយទៅវិញ សាមគ្គី៣ មានលក្ខណះដូចគ្នានឹងក្រុមសាមគ្គីស្វ័យភាពលើកលែងតែគោលការណ៍ពីយ៉ាងគឺក្រុមសាមគ្គីទី៣មានអង្គការក្រុមដឹកនាំនឹងគ្មានសិទ្ធិបែងចែកដី ។ រាល់សេចក្តីសម្រេចចិត្តអ្វីមួយ នៅក្នុងក្រុមត្រូវឆ្លងកាត់សេចក្តីសម្រេចចិត្តជារួមក្រោមការដឹកនាំសម្របសម្រួលការងារដោយប្រធានក្រុមសាមគ្គី ។ តួនាទីសំខាន់របស់មេក្រុម ស្ថិតនៅត្រង់ការតាមដានឥរិយាបទរបស់កសិករធ្វើការឃោសនាដើម្បីគាំទ្រដល់អំណាច ។

***ក្រុមសាមគ្គីបង្កបង្កើនផលប្រភេទទី២:***ក្រុមសាមគ្គី២មាន ប្រព័ន្ធដឹកនាំប្រហាក់ប្រហែលទៅនឹងប្រព័ន្ធកសិករខ្មែរជាប្រពៃណីទំនៀមទំលាប់ហៅថា"ប្រវាសដី" ។ រចនាសម្ព័នដឹកនាំនៅក្រុមសាមគ្គី២ជាប្រព័ន្ធវិលតទៅរកស្ថានភាពការពីដំណាក់កាលមុនសម័យអាណានិគមន៍និយមភាពខុសប្លែកគ្នាគ្រាន់តែនៅក្នុងក្រុមសាមគ្គី មានអង្គការចាប់តាំងដឹកនាំកសិករត្រឹមត្រូវជាងក្រុមប្រវាស់ដែលមានពីមុនមកកើតឡើងដោយការស្រុះស្រួលគ្នារវាងក្រុមនឹងគ្រួសារនីមួយៗ ។

*ក្រុមសាមគ្គីបង្កបង្កើនផលប្រភេទទី១*:ក្រុមសាមគ្គី-១មានចំនួនតិចណាស់បើប្រៀបធៀបទៅនឹងប្រភេទទី២នឹងទី៣ ហើយភាពខុសគ្នារឹតតែខ្លាំងរវាងក្រុមទី៣នៅលើប្រព័ន្ធបែងចែកផលិតផលនឹងការឧបត្ថម្ភ ។ ប្រព័ន្ធបែកចែកកសិផល ធ្វើឡើងដោយមានបីប្រភេទគឺ:

- ការបែកចែកតាមពលកម្មប្រចាំថ្ងៃ(តំបន់មានកសិផលល្អ)
- ការបែកចែកគ្នាតាមចំនួនសមាជិកគ្រួសារ(នៅតំបន់ទាំងឡាយមានការខ្វះខាតកសិផល)
- ការបែងចែកពាក់កណ្តាលតាមថ្ងៃពលកម្មនឹងពាក់កណ្តាលទៀតតាមចំនួនសមាជិកគ្រួសារ ។

ក្រុមសាមគ្គីប្រភេទ១ មានលក្ខណះប្រហាក់ប្រហែលនឹងកងធំជំនាន់របប ប៉ុលពត ដែលគេបែកចែកប្រជាជនទៅតាមកម្លាំងពលកម្មដែលមានបីប្រភេទគឺ កម្លាំងស្រួច កម្លាំងមធ្យមនឹងកម្លាំងទី៣(ចាស់ជរា កុមារ ជនពិការ )។ល។

***តួរលេខប្រចាំឆ្នាំដកស្រង់ចេញពីសៀវភៅ ហ៊ុន សែន "១០ឆ្នាំនៃដំណើរកម្ពុជា ភ្នំពេញ ១៩៨៩ ទំព័រ២៤៤"***

| ឆ្នាំ | ផ្ទៃដីស្រូវ ហិចតា | បរិមាណផល តោន |
|---|---|---|
| ១៩៧៩ | ៧៧០ ៥១០ | ២៦៥ ២២០ |
| ១៩៨០ | ១ ៤៤៤ ៤៧០ | ១ ៧១៥ ៣១០ |
| ១៩៨១ | ១ ៤៩១ ៦៥០ | ១ ៤៨៩ ៦១០ |
| ១៩៨២ | ១ ៦៨០ ៣៥០ | ១ ៩៨៩ ២០០ |
| ១៩៨៣ | ១ ៧៣៩ ៨៦០ | ២ ០៣៩ ២៥០ |
| ១៩៨៤ | ១ ៤២៦ ៧៨០ | ១ ២៥៨ ២៥០ |
| ១៩៨៥ | ១ ៥១៦ ០០០ | ១ ២៨៩ ៤៩០ |
| ១៩៨៦ | ១ ៦១៨ ១៤០ | ២ ០៨៦ ០៨០ |
| ១៩៨៧ | ១ ៤២៧ ២១០ | ១ ៨១៣ ៣៥០ |

- **ការអប់រំ**

គោលនយោបាយសំខាន់ខាងអប់រំក្នុងដំណាក់កាលនោះគឺ "អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះសោះ" ។ ព្រោះតែធនធានមនុស្សដែលជាអ្នកចេះដឹង

សល់ពីស្លាប់ដោយរបបវាលពិឃាតមានសេសសល់តិចតួចណាស់ ។ ប៉ុន្តែដោយសារពេលនោះសង្គមកម្ពុជាមិនទាន់មានការរត់ប្រណាំងគ្នាខាងសម្ភារៈនិយម ដូចរបបសេដ្ឋកិច្ចទីផ្សាសេរីនៅឡើយក្រោយថ្ងៃរំដោះជីវភាពប្រជាពលរដ្ឋ ស្ថិតក្នុងស្ថានភាពប្រហាលក់ប្រហែលគ្នា មន្ត្រីរាជការ ជាពិសេសគ្រូបង្រៀនមានឆន្ទៈតស៊ូខ្លាំងក្លាទោះបីរស់ក្នុងភាពអត់ឃ្លានក៏ដោយ ក៏នៅពុះពារសាងធនធានមនុស្សដោយយកចិត្តទុកដាក់ ។ ជាងនេះទៅទៀតមានការខិតខំប្រឹងប្រែងចាត់វិធានការណ៍ជាច្រើនបែបក្នុងការប្រយុទ្ធប្រឆាំងនឹងអនក្ខរកម្មនៅទូទាំងប្រទេសពេញមួយទសវត្សឆ្នាំ១៩៨០ ដែលធ្វើអោយអត្រាអ្នកមិនចេះអក្សរនៅមានចំនួនតិចបំផុត ។

## ៣.៤ នយោបាយបង្រួបបង្រួមជាតិនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

ក្រោយពីបានរំដោះប្រទេសកម្ពុជាចេញពីរបបកម្ពុជាប្រជាធិបតេយ្យរួចមក កម្ពុជាបានចាប់ផ្តើមបើកទំព័រប្រវិត្តសាស្ត្រជាថ្មី ក្នុងការកសាងទឹកដីរបស់ខ្លួនឡើងវិញ ។ ដោយមានការបើកចរចាជាច្រើនរវាងអ្នកដឹកនាំ និងការចរចារវាងប្រទេសផ្សេងៗក្នុងរឿង កម្ពុជា ដោយ ៖

- នៅឆ្នាំ១៩៨៥មានការចរចារវាង ចិន និងអាមេរិច ជាមួយ សហភាពសូវៀត នៅទីក្រុងហ្សឺណែវ ។
- នៅខែវិច្ឆកា ១៩៨៥ប្រទេសអឺរ៉ុបខាងលិច ជាពិសេសបារាំង បានរៀបចំការចរចារវាងព្រះបាទសីហនុ និង តំណាងរដ្ឋាភិបាល នៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ប៉ុន្តែត្រូវខកខានទៅវិញដោយ មានការរាំងពីសំណាក់ ចិន និងក្រុមខ្មែរក្រហម ។
- ១៩៨៧ មានការជួបគ្នាថ្នាក់កំពូលរវាង អាមេរិច និង សហភាពសូវៀតបានធ្វើឲ្យនយោបាយកម្ពុជាធូរស្រាលឡើង ។
- នៅឆ្នាំដដែលប្រទេសអឺរ៉ូបខាងលិចចង់ឲ្យមានការជួបចរចារវាងភាគីជម្លោះ គឺរដ្ឋាភិបាលត្រីភាគីកម្ពុជា ជាមួយវៀតណាមក្នុងការដកកង់ទ័ពចេញពីកម្ពុជា ទើបចរចាហើយដោះស្រាយដោយអង្គការសហប្រជាជាតិ ។ ទន្ទឹមនឹងនោះដែរឆ្នាំ ១៩៨៧ សម្តេច សីហនុ បានលាលែងពីដំណែងជាប្រមុខរដ្ឋាភិបាលត្រីភាគី ។
- ការដាក់ចេញនូវគោលនយោបាយបង្រួបបង្រួមជាតិ និងសំណើសន្តិភាព នៅខែ សីហា តុលា ១៩៨៧ ដើម្បីដោះស្រាយ ជំលោះរវាងព្រះបាទ សីហនុ រដ្ឋាភិបាល និង គូរជំលោះផ្សេងៗទៀត ។ នៅថ្ងៃទី២៩ កក្កដា ឆ្នាំ ១៩៨៧ រដ្ឋមន្ត្រី ការបរទេស ឥណ្ឌូណេស៊ី បានទស្សនកិច្ចនៅវៀតណាម ហើយបានធ្វើការពិភាក្សានៃការ ជួបគ្នារវាងគូបដិបក្ខ (កម្ពុជា) ជាពីរដំណាក់កាលគឺ ៖

  ១ ការជួបគ្នារវាងភាគីវិវាទទាំងពីរ

២ ការជួបគ្នារវាងភាគីទាំងអស់និងបណ្តាប្រទេសពាក់ព័ន្ធក្នុងដំណោះស្រាយនយោបាយនៅកម្ពុជា

➤ *ព្រឹត្តិការណ៍នៃការជួបគ្នាផ្សេងៗនៃដំណោះស្រាយ ៖*

- នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨៧ មានការជួបគ្នាលើកទី១រវាងសម្តេចសីហនុ និងលោកហ៊ុន សែន ហើយក៏មានការជួបនៅថ្ងៃទី៤ ធ្នូ ១៩៨៧នៅទីក្រុង ហ្វែអង់តាជឺន័រ ប្រទេសបារាំង រហូតដល់មានការចុះហត្ថលខានៃកិច្ចព្រមព្រៀងនិងចរចា ដើម្បីរកដំណោះស្រាយនៅកម្ពុជា ។
- សន្និសីទនៃបណ្តាប្រទេសអាស៊ានថ្ងៃទី ១៤-១៥ធ្នូ ១៩៨៧ បានថ្លែងការអបអរសាទរនៃការជួបគ្នារវាងសីហនុ និងលោក ហ៊ុន សែន ។
- នៅថ្ងៃទី២១-២២ មករា ១៩៨៨ ជាការជួបគ្នារវាងសម្តេច សីហនុ និងលោក ហ៊ុន សែន នាប្រទេសបារាំងគ្មានការប្រកាសអ្វីឡើយ ។
- នាខែ មេសា ១៩៨៨ ភាគីនីមួយៗបានលុបចោលការចរចាជាមួយសម្តេច សីហនុនៅព្យុងយ៉ាង ប្រទេសកូរ៉េខាងជើង ។
- នាខែ វិច្ឆកា ១៩៨៨ ភាគីនីមួយបានលុបចោលការចរចាជាមួយសម្តេច សីហនុ នៅប្រទេសបារាំង ។
- នៅដើមឆ្នាំ ១៩៨៩ ភាគីនីមួយបានលុបចោលការចរចាជាមួយសម្តេច សីហនុ នៅ ញូដេលីប្រទេសឥណ្ឌា ។ ក៏ប៉ុន្តែការជួបគ្នារវាង លោក ហ៊ុន សែន និង សម្តេច សីហនុ បានធ្វើឡើងជាបន្តបន្ទាប់ ប៉ារីស ហ្សាកាតា តូក្យូ និង ប៉ាតាយា ។
- នៅថ្ងៃទី ៣០ កក្កដា ដល់ថ្ងៃទី៣០ សីហា ១៩៨៩ នៅប៉ារីស មានការប្រជុំលើកទីមួយនៃសន្និសីទអន្តរជាតិស្តីពីកម្ពុជា ដែលមានប្រទេសបារាំង និងឥណ្ឌូនេស៊ី ជាសហប្រធានដែលពេលនោះភាគីខ្មែរបានព្រមព្រៀងគ្នាបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ នៅថ្ងៃទី១០ កញ្ញា ១៩៩០ មានសមាជិក១២រូបដែល ៦រូបមកពីរដ្ឋកម្ពុជា និង៦រូបទៀតមកពីត្រីភាគីនៅពេលនោះព្រះអង្គម្ចាស់នរោត្តមរណឬទ្ធិ ជាប្រធានគណបក្សហ៊ុនស៊ិនប៉ិចជំនួសព្រះបិតាឯករាជ្យដែលគង់នៅជាអព្យាក្រឹត្យ ។ ហើយក្រុមប្រឹក្សានេះបានកោះប្រជុំលើកទីមួយនៅ បាងកកប្រទេសថៃ និង ៥លើកទៀតនៅ ប៉ារីស ញូយ៉ក ហ្សាកាតា ប៉ាតាយ៉ា និងប៉េកាំង នៅទីបផុតក៏សម្រេចយកសម្តេច នរោត្តម សីហនុ ជាប្រធានក្រុមប្រឹក្សានេះ។
- នៅថ្ងៃទី២២ ដល់ ២៣ តុលា ១៩៩១ មានការប្រជុំលើកទី ២ នៅប៉ារីស និងបារាំង រវាងភាគីទាំង៤ គឺ រដ្ឋកម្ពុជា ហ៊ុនស៊ិនប៉ិច រណសិរ្សសង្គ្រោះជាតិ និងកម្ពុជាប្រជាធិបតេយ្យ ។ ហើយនៅថ្ងៃទី២៣ តុលា១៩៩១សម្តេច នរោត្តម សីហនុ បានចុះហត្ថលេខាលើកិច្ចព្រម

ព្រៀងរួមស្តីពីជម្លោះកម្ពុជា និងលើឯកសារ២ គឺ ១ ទាក់ទងអធិបតេយ្យភាពបូរណភាពដែនដី អព្យាក្រឹត្យ និងឯកភាពជាតិ និងទី២ ស្តីពីការស្តា និងកសាងប្រទេសកម្ពុជាឡើងវិញ ហៅថា កិច្ចព្រមព្រៀងក្រុងប៉ារីស ដែលមានប្រទេសចូលរួមចំនួន១៨ប្រទេស គឺ អូស្ត្រាលី ឥណ្ឌូនេស៊ី ប្រ៊ុយណេ កាណាដា ចិន អាមេរិក យូហ្គោស្លាវី បារាំង ឥណ្ឌា ជប៉ុន ឡាវ ថៃ ម៉ាឡេស៊ី ហ្វីលីពីន អង់គ្លេស សិង្ហបុរី សូវៀត និងវៀតណាម ហើយក៏មានការចូលរួមពីអគ្គលេខាធិការអង្គការសហប្រជាជាតិ និងចលនាមិនចូលបក្សសម្ព័ន្ធផងដែរ ។

## ៣.៥ ការរំដោះខេត្ត និងទីក្រុងនៃសាធារណរដ្ឋប្រជានិតកម្ពុជា

**ឈ្មោះខេត្តនិងទីក្រុងនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ៖**

1. **រដ្ឋធានីភ្នំពេញ**

   ថ្ងៃរំដោះ ០៧.០១.១៩៧៩ មាន ៤ ខណ្ឌ គឺដូនពេញ ចំការមន ៧មករា ទួលគោក និងមាន ៣ ស្រុកគឺ ឬស្សីកែវ មានជ័យ ដង្កោ ។

2. **ខេត្តកណ្តាល**

   ថ្ងៃរំដោះ ០៧.០១.១៩៧៩ ចម្ងាយពីភ្នំពេញ ១៣ គ.ម ទីរួមខេត្តតាខ្មៅ និងមាន១០ស្រុក គឺ ពញា កណ្តាលស្ទឹង មុខកំពូល ខ្សាច់កណ្តាល ស្អាង កៀនស្វាយ ល្វាឯម លើកដែក កោះធំ ភ្នំពេញ ។

3. **ក្រុងកំពង់សោម**

   ថ្ងៃរំដោះ ១៧.០១.១៩៧៩ ចម្ងាយពីភ្នំពេញ ២៣០ គ.ម មាន ២ ខណ្ឌ គឺ ស្ទឹងហាវ មិត្តភាព និងមាន ១ ស្រុកគឺ ព្រៃនប់ ។

4. **ខេត្តកំពង់ចាម**

   ថ្ងៃរំដោះ ០៦.០១.១៩៧៩ ចម្ងាយពីភ្នំពេញ ១២៨ គ.ម ទីរួមខេត្តកំពង់ចាម និងមាន ១៥ ស្រុក គឺ តំបែរ ក្រូចឆ្មា កោះសូទិន ព្រៃឈរ ត្បូងឃ្មុំ មេមត់ ចំការលើ ស្ទឹងត្រង់ ស្រីសន្ធរ ពញាក្រែក ជើងព្រៃ កំពង់សៀម អូរាំងឪ កងមាស និង បាធាយ ។

5. **ខេត្តស្វាយរៀង**

   ថ្ងៃរំដោះ ០៤.០១.១៩៧៩ ចម្ងាយពីភ្នំពេញ ១២៤ គ.ម ទីរួមខេត្តស្វាយរៀង និងមាន៦ ស្រុក គឺរមាសហែក កំពង់រោទិ៍ រំដួល សន្ទ្រា ស្វាយទាប និងស្វាយរៀង ។

6. **ខេត្តព្រៃវែង**

   ថ្ងៃរំដោះ ០៨.០១.១៩៧៩ ចម្ងាយពីភ្នំពេញ ៩១ គ.ម ទីរួមខេត្តព្រៃវែង និងមាន១១ស្រុក គឺ ពារាំង កំពង់ត្របែក ព្រៃវែង មេសាង បាភ្នំ ស៊ីធរកណ្តាល កំចាយមារ កញ្ច្រៀច ពាមរ ពាមជ័រ និងព្រះស្តេច។

7. **ខេត្តតាកែវ**

ថ្ងៃរំដោះ ០៨.០១១៩៧៩ មានចម្ងាយពីភ្នំពេញ ៨៧ គ.ម ទីរួមខេត្ត តាកែវ ស្រុក៩គឺ ត្រាំកក់ គីរីវង្ស ទ្រាំង បាទី ព្រៃកប្បាស កោះអណ្តែត សំរោង អង្គរបុរី បូរីជលសារ ។

8. **ខេត្តកំពង់ធំ**

ថ្ងៃរំដោះ ០៩.០១.១៩៧៩ ចម្ងាយពីភ្នំពេញ ១៦១ គ.មទីរួមខេត្ត កំពង់ធំ ស្រុក ៦ គឺ បារាយ៍ ស្ទោង សន្ទុក សណ្តាន់ កំពង់ស្វាយ ប្រាទសំបូរ ។

9. **ខេត្តសៀមរាប និងឧត្តរមានជ័យ**

ថ្ងៃរំដោះ ១០.០.១៩៧៩ ចម្ងាយពីភ្នំពេញ ៣១៥គ.ម ទីរួមខេត្តសៀមរាបស្រុក ១៣ គឺ បន្ទាយស្រី វ៉ារិន ស្រីស្នំ សូត្រនិគម ជីក្រែង ក្រឡាញ់ ពួក សៀមរាប អង្គរធំ អង្គរជុំ ស្វាយលើ សំរោង ចុងកាល ។

10. **ខេត្តពោសាធិ៍សាត់**

ថ្ងៃរំដោះ ១៥.០១.១៩៧៩ ចម្ងាយពីភ្នំពេញ ១៨៦គ.ម ទីរួមខេត្ត ពោធិ៍សាត់ ស្រុក ៤ គឺ ក្រគរ ភ្នំក្រវ៉ាញ កណ្តៀង បាកាន ។

11. **ខេត្តបាត់ដំបង**

ថ្ងៃរំដោះ ១៣.០១.១៩៧៩ ចម្ងាយពីភ្នំពេញ ២៩១ គ.ម ទីរួមខេត្ត បាត់ដំបង ស្រុក៧ គឺ បាត់ដំបង សង្កែ មោងឬស្សី រតនះមណ្ឌល បរវេល បាណន់ ឯកភ្នំ ។

12. **ខេត្តកំពង់ឆ្នាំង**

ថ្ងៃរំដោះ ១២.០១.១៩៦៧៩ ចម្ងាយពីភ្នំពេញ ៩៣ គ.ម ទីរួមខេត្ត កំពង់ឆ្នាំង ស្រុក៧ គឺ បរិបូរណ៍ រលប្អៀរ ទឹកផុស កំពង់លែង កំពង់ត្រឡាច សាមគ្គីមានជ័យ ជលគីរី ។

13. **ខេត្តកំពត**

ថ្ងៃរំដោះ ០៩.០១.១៩៧៩ ចម្ងាយទីភ្នំពេញ ១៤៨គ.ម ទីរួមខេត្តកំពត ស្រុក៧គឺ អង្គរជ័យ ឈូក កំពត កំពង់ត្រាច បន្ទាយមាស ដងទង់ ជុំគីរី ។

14. **ខេត្តកោះកុង**

ថ្ងៃរំដោះ ១៧.០១.១៩៧៩ ចម្ងាយពីភ្នំពេញ ៣៥០ គ.ម ទីរួមខេត្តកោះកុង ស្រុក ៦គឺ ស្រែអំបិល ថ្មបាំង បុទុមសាគរ កោះកុង មណ្ឌលសីម៉ា គីរីសាគរ ។

15. **ខេត្តកំពង់ស្ពឺ**

ថ្ងៃរំដោះ ០៩.០១.១៩៧៩ ចម្ងាយពីភ្នំពេញ ៤៨ គ.ម ទីរួមខេត្តកំពង់ស្ពឺ មានស្រុក ៧ គឺ គងពិសី សំរោងទង ឧត្តុង្គ ភ្នំស្រួច ថ្ពង បសេត ឪរ៉ាល់ ។

**16.ខេត្តព្រះវិហារ**

ថ្ងៃរំដោះ ១៦.០១.១៩៧៩ មានចម្ងាយពីភ្នំពេញ ២៩២ គ.ម ទីរួមខេត្តព្រះវិហារ មានស្រុក ៦គឺ សង្គមថ្មី គូលែន រវៀង ជ័យសែន ឆែប ជាំក្សាន្ត ។

**17.ខេត្តស្ទឹងត្រែង**

ថ្ងៃរំដោះ ០៤.០១.១៩៧៩ ចម្ងាយពីភ្នំពេញ ៤៨១ គ.ម ទីរួមខេត្តស្ទឹងត្រែង មានស្រុក៤ គឺ សៀមបូក សេសាន សៀមប៉ាង ថាឡាបរីវ៉ាត់ ។

**18.ខេត្តរតនគីរី**

ថ្ងៃរំដោះ ៣១.១២.១៩៧៨ ចម្ងាយពីភ្នំពេញ ៦៣៤ គ.ម ទីរួមខេត្តរតនគីរី មានស្រុក ៧ គឺបានលុង វឺនសៃ បកែវ លំផាត់ តាវែង យ៉ាដាវ អណ្តូងមាស កូនមុំ ។

**19.ខេត្តមណ្ឌលគីរី**

ថ្ងៃរំដោះ ០៣.០១.១៩៧៩ មានចម្ងាយពីភ្នំពេញ ៥៤៣ គ.ម ទីរួមខេត្តមណ្ឌលគីរី មានស្រុក ៤ គឺ សែនមនោរម្យ អូររាំង កោះញែក ពេជចិន្តា កែវសីម៉ា ។

**20.ខេត្តក្រចេះ**

ថ្ងៃរំដោះ ៣០.១២.១៩៧៨ មានចម្ងាយពីភ្នំពេញ ៣៤០ គ.ម ទីរួមខេត្តក្រចេះ មានស្រុក ៥គឺ ក្រចេះ ព្រែកប្រសព្វ ស្នួល ឆ្លូង សម្បូរ ។

**21.ខេត្តបន្ទាយមានជ័យ**

ជាខេត្តដែលបានបង្កើតថ្មីដោយការកាត់ទឹកដីពីខេត្តបាត់ដំបង ហើយខេត្តនេះមានផ្ទៃដី ៨.៧៥៥ គ.ម.ការេ មានចម្ងាយពីភ្នំពេញ ៣៥១ គ.ម ទីរួមខេត្តសិរីសោភណ្ឌ័ មានស្រុក ៦គឺ ថ្មពួក មង្គលបូរី សិរីសោភណ្ឌ័ ភ្នំស្រុក ព្រះនេត្រព្រះ បន្ទាយអំពិល ។

ទង់ជាតិសាធារណរដ្ឋប្រជាមានិតកម្ពុជា ១៩៧៩-១៩៨៩ ត្រូវបានបង្កើតឡើងដែលមានមាត្រដ្ឋានដូចទង់ជាតិ កម្ពុជាប្រជាធិបតេយ្យ ដែលមានសណ្ឋានផ្ទៃពណ៌ក្រហមប៉ុន្តែមានប្រាសាទកំពូល ៥ (ពណ៌លឿង) ហើយត្រូវប្រើរហូតដល់ឆ្នាំ ១៩៨៩ ប៉ុន្តែពុំបានទទួលស្គាល់ឆាកអន្តរជាតិជាពិសេសអង្គការសហប្រជាជាតិ ។

# ជំពូកទី ៤
# វិភាគបញ្ហានៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា

## ៤.១ ចំណុចខ្សោយ

រហូតមកដល់ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៨៥ មានចំនួនពលករ២៩៥៦នាក់ហើយចំនួនតាមផែនការ៣១៥០នាក់ ។ ក្នុងចំនោមចំនួន២៩៥៩នាក់មានៈ

➡៧៤៥នាក់នៅក្នុងមន្ទីរពេទ្យ(៥២នាក់ជាពលកររងរបួស)

➡៦០២នាក់មានជំងឺនឹងទាមទារការមើលថែទាំជាចំបាច់

➡៣២នាក់ស្លាប់ក្នុងសម

➡១៤៤នាក់រត់ចោលការងារ

ហើយនៅសល់១៤៣៣នាក់ក្នុងចំនោមពួកគេទាំងនេះក៏មានជំងឺនឹងទទួលការព្យាបាលអំឡុងពេលកំពុងបំពេញការងារ ។ នៅក្នុងផែនការក៥បានបានដេញប្រជាជនដើម្បីការពារប្រទេសជាតិបានស្លាប់ជាពិសេសគឺបុរសៗត្រូវស្លាប់នៅសមរភូមិអស់ជាច្រើននាក់មានជំងឺនៅពេលបំពេញការងារមូលហេតុនៃការកើតជំងឺគឺមកពីភាពទន់ខ្សោយនៃប្រព័ន្ធផ្គត់ផ្គង់ម្ហូបអាហារពីព្រោះរដូវភ្លៀងឆ្នាំនោះមានរយៈពេលវែងជាងធម្មតាដែលធ្វើអោយយឺតយ៉ាវដល់ដំណើរការដឹកជញ្ជូនចំណីអាហារហើយពលករក្រីក្ររជាច្រើនពុំទទួលបាននូវការផ្គត់ផ្គង់អោយបានគ្រប់គ្រាន់ទេ (តាមសេចក្តីរាយការណ៍កម្មករស់នៅដោយហូបបាយនឹងអំបិល) ជាហេតុអ្វីអោយពលករងាយរងនូវជំងឺជាច្រើនមុខជាពិសេសគឺជំងឺគ្រុនចាញ់ ។ ហេតុផលមួយទៀតគឺកង្វះអនាម័យការប្រកាន់ខ្ជាប់នៅការអនុវត្តន៍មិនបានល្អដូចជា ការកាប់ឆ្ការព្រៃជុំរកម្ទសនិងការដេកក្នុងមុង និងការហូបទឹកស្អាត គឺជាកត្តាកាត់បន្ថយជំងឺ ។ រដ្ឋាភិបាលមានប្រព័ន្ធមួយផ្តល់ មុងអោយពលករទាំងអស់ប៉ុន្តែតាមការពិតពលករមួយចំនួននៅតែគ្មានមុងសម្រាប់ការពារដដែល ។ របាយការណ៍ខែ កុម្ភៈ ឆ្នាំ ១៩៨៦ បានជំរុញអោយក្រសួងសុខាភិបាលផ្តល់ថ្នាំនិងធ្វើការព្យាបាលអោយបានគ្រប់គ្រាន់ដល់ពលករតាមព្រំដែន ប៉ុន្តែគេទទួលស្គាល់ថា តាមពិតការបើកនូវស្តុកថ្នាំក្នុងឆ្នាំ ១៩៨៤ដល់១៩៨៥ បានធ្លាក់ចូលអ្នកជំនួញឯកជនមួយចំនួន ។ ការកេងកម្លាំងគឺជាសកម្មភាពដែលប្រជាពលរដ្ឋមិនចូលចិត្ត ហេតុដូចនេះហើយទើបប្រជាជនមួយចំនួនបានធ្វើការស្វែងរកជំរកក្នុងជំរុំតាមព្រំដែនថៃ ។ ហើយវាក៏ជំរុញអោយមានការផ្តល់ឱកាសអោយមន្ត្រីពុករលួយធ្វើការបង្កើតទ្រព្យសម្បិត្តដែល ។ ពួកគេបានធ្វើការប្រមូលថវិការជា

ប្រចាំខែពីគ្រួសារអ្នកដែលមិនអោយកូនរបស់ខ្លួនទៅបំរើក្នុងកងទ័ព ។ មន្ត្រីទាំងនេះក៏ត្រូវបាន គេសូកអោយកេណ្ឌមនុស្សរំលូសដោយមនុស្សផ្សេងៗទៀត ។ ការសូកប៉ាន់ត្រូវបានគេហៅជាទូទៅថា (ស៊ីឈ្នួលជួលមនុស្ស) ។ ការកេញកេណ្ឌកងទ័ពពលករទីណាដែលមានផ្ទុកការងារធ្ងន់ធ្ងរតែងតែធ្លាក់ទៅលើប្រជាជនកម្ពុជាតាមស្រុកស្រែអ្នកដែលគ្មានលុយមធ្យោបាយជៀសផុតបាន ។ ការដាក់កំរិតយ៉ាងខ្លាំងលើភាពចលនានិងភាពខ្លាំងក្លានៃសេចក្តីបង្គាប់ដែលស្តីពីការវាយប្រហាសត្រូវនេះបានធ្វើអោយតាមទីជនបទក្លាយជាកន្លែងកំរាមកំហែងបំផុតក្នុងពាក់កណ្តាលឆ្នាំ ១៨៨៥ ។

## ៤.២ ចំណុចខ្លាំង

បានទប់ស្កាត់ពីពួកប៉ុលពតនិងពួកខ្មែរក្រហមមិនឲកកើតឡើងជាថ្មីម្តងទៀតនិងពិសេសមួយទៀតនោះគឺយកបានឯកសាររបស់ពួកប៉ុលពតទាំងអស់។ក្នុងអំឡុងឆ្នាំគ្រប់គ្រងដោយលោកចាន់ស៊ី(១៩៨២-១៩៨៤) គេបានបង្កើតកម្មវិធីប្រលងប្រណាំងក្នុងចំនោមកម្មករ ទាហាន កសិករ និងសិស្សនិស្សិត ហើយអ្នកចូលរួមធ្វើការប្រកួតប្រជែង ដើម្បីការ ការពារ និងកសាងជាតិ នឹងត្រូវបានគេគោរពផ្តល់រង្វាន់ជាថវិការនិងទង់ជ័យជំនះ។ ចលនាប្រលងប្រណាំងត្រូវបានប្រកាសរួមនិងអំពាវនាវដល់កម្លាំងបដិវត្តន៍របស់បក្សនាថ្ងៃទី២ខែតុលាឆ្នាំ ១៩៨២។ការប្រការនេះមានសេចក្តីថា"បដិវត្តន៍គឺជាបុព្វហេតុរបសប្រជាជន"ដូច្នេះ ចាំបាច់ត្រូវមានចលនាចូលរួមយ៉ាងសកម្មពីប្រជាជនប្រយោជន៍ឬភាពសំខាន់នៃការប្រលងប្រណាំងដំបូងដែលគេហៅថា"ស្នេហាជាតិ"មានដូចខាងក្រោម÷

- ➡ដើម្បីវាយប្រហារសត្រូវ
- ➡ដើម្បីផលិតអោយបានច្រើន
- ➡ដើម្បីធ្វើការងារអោយមានប្រសិទ្ធភាព
- ➡ដើម្បីមានការភ្ញាក់រលឹកខ្ពស់នូវការថែរក្សា ការពារ ទ្រព្យសម្បត្តិរដ្ឋនិងទ្រព្យសម្បត្តិប្រជាជន។ការិយាល័យ និងក្រុមប្រឹក្សាក្រោយមកបានធ្វើការរួមគ្នានិងការងារគ្រប់គ្រងរបស់"ក៥"ដើម្បីជួយកេណ្ឌនិងលើកទឹកចិត្តប្រជាជនអោយចូលរួមក្នុងកិច្ចការការពារព្រំដែន។តាមការពិតប្រព័ន្ធនិងរបៀបធ្វើការងាររបស់"ក៥"គឺជាភាពជាប់គ្នានៃចលនាប្រមូលផ្តុំទាំងនោះ។

ខឿនសេដ្ឋកិច្ចរបស់សាធារណៈរដ្ឋប្រជាមានិតកម្ពុជា ជាសេដ្ឋកិច្ចនិយម ។ ទឹក ដី ព្រៃ ភ្នំ ស្ទឹង បឹង ព្រែក ទន្លេ សមុទ្រ រ៉ែក្រោមដី អាកាស និងរោចក្រផលិតកម្មទាំងអស់ ជារបស់រដ្ឋ។ បានរៀបចំឲមាន«ក្រុមសាមគ្គីបង្កបង្កើនផល»។ តែក្រុមសាមគ្គីនេះ មិនមែនបែបសហករណ៍ប្រមូលផ្តុំ«ដាក់កម្មសិទ្ធរួម ហូបរួម»ដូចរបបខ្មែរក្រហមឡើយ។ ម្លោះហើយគ្រួសារណាក៏ដោយ

ក៏អាចរស់នៅបានតាមរបៀបប្រវាស់ដៃ និងទទួលចំណែកភោគផលតាមកម្លាំងពលកម្មនោះបានដែរ។

ការលើកកម្ពស់កម្រិតជីវភាពកងទ័ព និងគ្រួសារតាមប្រភពពត៌មានមួយចំនួនបានពន្យល់ថា អាជ្ញាធរខេត្តកម្ពុជាទាំងអស់មានកាតព្វកិច្ចឧបត្ថម្ភជាកញ្ចប់គ្រឿងបរិភោគ និងឧបភោគដែលរៀបចំជាស្រាចជូនដល់កងទ័ព។ កាសែត "កងទ័ពបដិវត្តន៍" បានសរសេរថា "ដោយយោងតាមមាគានយោបាយនៃបក្សប្រជាជនបដិវត្តន៍កម្ពុជា និងរដ្ឋាភិបាលកម្ពុជាមានទិសដៅជំរុញឱ្យពង្រឹងកម្លាំងទ័ព លើកកម្ពស់ជីវភាពកងកម្លាំងប្រយុទ្ធ បណ្តាខេត្តទាំងអស់នៃសាធារណរដ្ឋប្រជាមានិតកម្ពុជាមាននាទីឧបត្ថម្ភដល់កងទ័ពបដិវត្តន៍កម្ពុជា។ គ្រាន់តែនៅក្នុងពាក់កណ្តាលឆ្នាំ១៩៨៤ ខេត្តកណ្តាលបានឧបត្ថម្ភដល់កងទ័ពចំនួនគោ៣៦ក្បាល ជ្រូក១៣០ក្បាល ស្ករត្នោត១០តោន និងគ្រឿងបរិភោគជាច្រើនទៀត។ ខេត្តបាត់ដំបង ពោធិ៍សាត់ ព្រៃវែងក៏ឧបត្ថម្ភដល់កងទ័ពយ៉ាងច្រើនសន្ធឹកសន្ធាប់ដែរ។

គោលនយោបាយសំខាន់ខាងអប់រំ ក្នុងដំណាក់កាលនោះ គឺ "អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះសោះ"ព្រោះធនធានមនុស្សដែលជាអ្នកចេះដឹងដែលសល់ពីស្លាប់ដោយរបបវាលពិឃាតមានសេសសល់តិចតួចណាស់។ ប៉ុន្តែដោយសាពេលនោះសង្គមកម្ពុជាមិនទាន់មានការរត់ប្រណាំងគ្នាខាងសម្ភារនិយម ដូចរបបសេដ្ឋកិច្ចទីផ្សាសេរីនៅឡើយ ក្រោយថ្ងៃរំដោះជីវភាពប្រជាពលរដ្ឋ ស្ថិតក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា មន្ត្រីរដ្ឋការជាពិសេសគ្រូបង្រៀន មានឆន្ទៈតស៊ូធ្វើកាខ្លាំងក្លា ទោះបីរស់នៅក្នុងជីវភាពអត់ឃ្លានក៏ដោយ ក៏នៅតែពុះពារ កសាងធនធានមនុស្សដោយយក់ចិត្តទុកដាក់។ វិស័យអប់រំមានការីកចំរើនទោះបីកាលៈទេសៈប្រទេសស្ថិតក្នុងភាពអសន្តិសុខក៏ដោយ។ ជាងនេះទៀត មានកាខិតខំប្រឹងប្រែងចាត់វិធានការជាច្រើនបែប ក្នុងការប្រយុទ្ធប្រឆាំងនឹងអនក្ខកម្មនៅទូទាំងប្រទេស ពេញមួយសតវត្សរ៍ឆ្នាំ១៩៨០ដែលធ្វើឱ្យអ្នកមិនចេះអក្សរនៅមានចំនួនតិច។ ចំណែក អំពើពុករលួយក្នុងវិស័យនេះ ក៏មានបរិមានតិចតួចដែរ ដោយសារមានការចោទប្រកាន់ពីបទពុករលួយ និងអំពើបក្សពួកនិយមពីមហាជនទូទៅ និងពីក្រុមសិស្សដែលប្រឡងធ្លាក់ជាច្រើន។ ដូចជាពាក្យស្លោកថា«កូនអ្នកក្រធ្វើទាហាន កូនអ្នកមានធ្វើនគរបាល កូនកម្មាភិបាលទៅរៀននៅបរទេស»។ ព្រោះគេឃើញអ្នកដែលពេញវ័យ មិនរៀនតាមសាលា មុខជាអាចត្រូវគេចុះឈ្មោះឱ្យធ្វើជាកងទ័ព។ កេណ្ឌកម្លាំងទៅកាប់ឆ្ការព្រៃឈើដើម្បីកំចាត់ខ្មាំងដើម្បីកំអោយ(ពួគប៉ុលពតកកើតឡើងវិញ)។ ដោយសារបានផែនការក៥នេះហើយទើបធ្វើអោយប្រទេសជាតិមានសុខសន្តិភាពគ្រាន់បើឡើងមួយរយៈ ។ តួលេខប្រចាំឆ្នាំដកស្រងចេញពីសៀវភៅ ហ៊ុន សែន ផ្នែកកសិកម្ម១០ឆ្នាំនៃដំណើរកម្ពុជាភ្នំពេញឆ្នាំ ១៩៨៩ទំព័រ២៥៤។

| *ឆ្នាំ* | *ផ្ទៃដីស្រូវ-ហិតា* | *បរិមាណផលតោន* |
|---|---|---|
| ១៩៧៩ | ៧៧០ ៥១០ | ២៦៥ ២២០ |
| ១៩៨០ | ១ ៤៤៤ ៤៧០ | ១ ៧១៥ ៣១០ |
| ១៩៨១ | ១ ៤៩១ ៦៥០ | ១ ៥៨៩ ៦១០ |
| ១៩៨២ | ១ ៦៨០ ៣៥០ | ១ ៩៨៩ ២០០ |
| ១៩៨៣ | ១ ៧៣៩ ៨៦០ | ២ ០៣៩ ១៩០ |
| ១៩៨៤ | ១ ១៩៦ ៧៨០ | ១ ២៥៨ ២៥០ |
| ១៩៨៥ | ១ ៥១៦ ០០០ | ១ ៧៨៩ ៤៩០ |
| ១៩៨៦ | ១ ៦១៨ ១៤០ | ២ ០៨៦ ០៨០ |
| ១៩៨៧ | ១ ៤២៧ ២១០ | ១ ៨១៣ ៣៥០ |

នៅលើវិស័យនយោបាយកសិកម្មពុំមានប្រែប្រួលយ៉ាងធំធេងណាស់ដែលកសិករមានសិទ្ធធ្វើអាជីវកម្មលើដីធ្លីរបស់ខ្លួនដោយសេរីនឹងសិទ្ធក្នុងការបែងចែកផលិផលរបស់ខ្លួន ។

# ជំពូកទី ៥ សន្និដ្ឋាន និងអនុសាសន៍

តាមរយៈការអធិប្បាយខាងលើបានបង្ហាញថា ប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៧ កំពុងច្របូកច្របល់រវាងប្រទេសទីបីដែលជាប្រទេសជិតខាងដែលជាហេតុនាំអោយមានកងទ័ព និង ប្រជាជននៅភូមិភាគបូព៌ារត់ទៅប្រទេសវៀតណាម៕ រីឯវៀតណាមក៏មានផែនការបញ្ជូនប្រជាជនមកកាន់កម្ពុជាវិញដែល។ ទន្ទឹមនិងនោះផងដែលជាហេតុដែលវៀតណាមបង្រួបបង្រួមក្រុមភៀសខ្លួន រួចបញ្ជូនចូលមកក្នុងទឹកដីខ្មែរភាគខាងកើត ហើយក៏បានរៀបចំបង្កើត "រណសិរ្សសាមគ្គីសង្រ្គោះជាតិកម្ពុជា" ដើម្បីប្រយោជន៍ដ៏ធំសម្រាប់សង្រ្គោះប្រជាជនកម្ពុជាពីមាត់រណណ្ដៅពិឃាត ដោយមានជំនួយពីវៀតណាម។ការវាយប្រហាខ្មែរក្រហមបានជោគជ័យហើយ ក្រោយមកក៏មានការកែប្រែរណសិរ្សនេះកំឡុងពេលបង្កើកសារធារណប្រជាមានិតកម្ពុជាក៏បានកែប្រែជា" រណសិរ្សសាមគ្គីកសាងការពារមាតិភូមិ" នៅឆ្នាំ១៩៧៩។ ដោយយើងដឹងថាកម្ពុជានាសម័យនោះ មានស្ថាប័នបីដែលគ្រប់គ្រងដោយបក្សតែមួយដែលមាន អង្គការនីតិបញ្ញត្តិ-សភា នីតិប្រតិបត្តិរដ្ឋាភិបាល និងអង្គការតុលាការប្រជាជនបដិវត្តន៍នៅតាមខេត្ត-ក្រុងនានាទូទាំងប្រទេស។ បន្ទាប់ពីប្រជា ១៩៧៩មកប្រជាជនក៏បានស្វះស្វែងរកលំនៅដ្ឋាន បងប្អូនញាតិសណ្ដានដែលបានបែកគ្នាក្នុងរបបប្រល័យពូជសាសន៍នេះបានអូសបន្លាយពេលអស់១ឆ្នាំ។បន្ទាប់ពីប្រជាជនកម្ពុជា រួចផុតពីក្រញ៉ាំពិឃាតរបស់យុត្តមិត្តបដិវត្តន៍ ដែលបណ្ដុះបណ្ដាលដោយប៉ុលពត យើងឃើញថា សាធារណរដ្ឋប្រជាមានិតកម្ពុជា មានគោលដៅក្នុងការកសាងប្រទេសជាជំហ៊ានៗឆ្លងកាត់អន្តរកាលឆ្ពោះទៅរកសង្គមនិយម។ ហើយខឿនសេដ្ឋកិច្ចរបស់សាធារណរដ្ឋកម្ពុជា ជាសេដ្ឋកិច្ចសង្គមនិយមគឺ ទឹក ដី ព្រៃ ភ្នំ ស្ទឹងបឹង ព្រែក ទន្លេ សមុទ្ររ៉ែក្រោមដី អាកាស និងរោចក្រផលិតកម្មទាំងអស់ ជារបស់រដ្ឋ។ តាមការពិត ការកំណត់ទិសដៅនេះ គេមិនបានឃើញមានវិធានការណ៍ សម្រាប់ការអភិវឌ្ឍន៍យូរអង្វែងទៀតឡើយ ដូចជា ការជំរុញអោយមានការចិញ្ចឹមត្រីប្រពលវប្បកម្ម ការដាំដុះព្រៃឈើឡើងវិញ ឬការយកចិត្តទុកដាក់ស្ដារ នឹងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ និងបង្កើតថ្មីៗទៀតឡើយ។ បើគេប្រៀបធៀបទៅនឹងរបបកុំមម្មុននីស្តខ្មែរក្រហមពីអតីតកាល ដែលវិនាសផុតទៅ លោក ឆាណ្ឌល័រ និង លោក វិយើរី(១៩៨៣: ២២៥ cited in Chandler, 2000:230) ដែលបានវាយតម្លៃថា "គោលននយោបាយរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ននិងវៀតណាមដែលជាខ្នងបង្អែករបស់គេ មានលក្ខណៈព្រហ្មវិហារធម៌, សំអាងលើការប្រតិបត្តិ ននិងមិនបង្ខិតបង្ខំ" ។ ហើយនៅថ្ងៃទី ៣ តុលា ១៩៨៥ រដ្ឋាភិបាលបានកំណត់កាតព្វកិច្ចយោធារយៈពេល៥ឆ្នាំសម្រាប់ពលរដ្ឋខ្មែរ

ប្រុសស្រីម្នាក់ៗចាប់ពីអាយុ១៨ឆ្នាំឡើងទៅ ។ ក្នុងនោះដែរ ក៏កំណត់កាតព្វកិច្ចយោធាសម្រាប់យុវជនយុវនារីដែលមានអាយុចាប់ពី១៦ឆ្នាំឡើងដែរ ដើម្បីជុំរុញការអនុវត្តន៍ផែនការ"ក៥" ដែលជាផែនការកាប់ឆ្ការព្រៃក្នុងទ្រង់ទ្រាយធំរបស់រដ្ឋាភិបាល នៅតាមបណ្តោព្រំដែនកម្ពុជា-ថៃ ដើម្បីផលប្រយោជន៍ដែលគេហៅថា "បំផ្លាញជម្រកខ្មាំង" នៅតាមព្រំដែន ។ សូមបញ្ជាក់ថា យុទ្ធនាការកាប់បំផ្លាញព្រៃឈើនេះ មិនមែនមាននៅតែតាមព្រំដែនប៉ុណ្ណោះទេតែនៅតាមតំបន់ជនបទ ក៏មានការបញ្ជារអោយកាប់ឆ្ការព្រៃឈើក្បែរភូមិ ដើម្បីបំផ្លាញជម្រកលាក់ខ្លួនរបស់ខ្មាំងសត្រូវដែរ ។ មានរឿងរ៉ាវសោកនាដ្យកម្មច្រើន ទាក់ទងនឹងការបំពេញកាតព្វកិច្ចក៥របស់ប្រជាពលរដ្ឋខ្មែរ ដោយសារការប្រឈមមុខននឹងសេចក្តីស្លាប់ ដោយសារគ្រាប់ផ្លោងរបស់ភាគីចលនាតស៊ូ, ការវាយប្រហារគ្រង់ៗ, ការដើរជាន់មីន និងជំងឺផ្សេងៗ ជាពិសេសគ្រុនចាញ់ ទើបប្រជាជានាខ្មែរភាគច្រើន តែងតែប៉ុនប៉ងគេចវេសពីការបំពេញកាតព្វកិច្ចនេះ ។ ផែនការក៥នេះបានក្លាយទៅជាគោលននយោបាយមួយកាន់តែគ្មានប្រជាប្រិយភាព របស់សាធារណរដ្ឋប្រជាមានិតកម្ពុជា បើតាមការធ្វើកំណែនក្នុងឆ្នាំ១៩៨៥-១៩៨៦ ។ បញ្ហានេះលោក ប៉ែន សុវណ្ណ ដែលជាអតីតនាយករដ្ឋមន្ត្រីទី១នៃរបបនេះ បានអះអាងថា ក-៥ គឺជាផែនការកំណត់ដោយវៀតណាម ។ ពោលមិនមែនជាគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលភ្នំពេញឡើយ ។ ហើយនៅក្នុងរបបនោះបានបញ្ជាក់ថា គោលនយោបាយសំខាន់ខាងអប់រំ ក្នុងដំណាក់កាលនោះ គឺ "អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះសោះ" ដោយសារប្រជាជនទើបរួចផុតពីរបបពិឃាតដែលដឹកនាំដោយ ប៉ុល ពត ទើបធ្វើអោយមានការអត់ថយខាងធនធានមនុស្ស ប៉ុន្តែក៏នៅមានសេសសល់អ្នកចេះដឹងតិចតួចដែល ដែលបានរួចផុតពីរបបនោះក៏បានជួយបង្ហាត់បង្រៀនក៏ដូចជាជួយសាងធនធានមនុស្សដោយយកចិត្តទុកដាក់ទោះបីរស់នៅក្នុងភាពអត់ឃ្លានយ៉ាងណាក៏ដោយ ។ ទាក់ទងនឹងជំនួយការបរទេស លោក ឆាណ្ឌល័រ (២០០០:២២៨-២៣០)បានបញ្ជាក់ថាមានប្រជាជនខ្មែរតិចណាស់ដែលទ្រាំរស់នៅនិងធ្វើសកម្មភាពដដែលៗ ដូចនៅកំឡុងឆ្នាំ១៩៧៩-១៩៨០ ធ្វើស្រែយកស្រូវសល់ពីរបបមុនដែលវៀតណាមបានប្រូលយកទុកអោយកងទ័ពរបស់ខ្លួនជាហេតុដែលធ្វើអោយប្រជាពលរដ្ឋខ្មែររាប់សែននាក់នៅសល់ស្បៀងតិចណាស់ស្ទើតែគ្មានអ្វីសម្រាប់បរិភោគតែម្តង ។ ហើយទុក្ខវេទនានេះបានអំពាវនាវអោយមានការ ឧបត្ថម្ភអំណោយស្បៀងអាហារពីក្រៅប្រទេសនានា ។ ក្រៅពីនេះ រដ្ឋាភិបាលខ្មែរទទួលបានតែជំនួយពីសហព័ន្ធសូវៀត និង សម្ព័ន្ធមិត្តនៅក្នុងប្លុកកុំមុយនុសជាមួយគ្នាតែប៉ុនោះ ដោយមិនបានទទួលការឧបត្ថម្ភជួយសង្រោះពីប្រទេសវៀតណាមឡើយ ។ ចំនែកឯកងកម្លាំងប្រជាធិតេយ្យវិញបានការវាយប្រហារអោយបរាជ័យគ្រប់សមរភូមិពីកងទ័ពវៀតណាមក៏បានពុះពាររត់ដកថយរកទីកន្លែងដែលជាទីបង្អែកសម្រាប់ធ្វើក្បួនយុទ្ធសាស្ត្រ ដើម្បីបន្តសកម្មភាព

ក្នុងទ្រង់ទ្រាយសង្គ្រាមឈ្លបតាមក្រុមតូចៗអុកឡុកបង្កអសន្តិសុខដល់រដ្ឋាភិបាលសាធារណប្រជាមានិតកម្ពុជាជារៀងរាល់ថ្ងៃ ។ មកដល់ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ១៩៨០ សម្តេច សីហនុ បានស្នើខៀវសំផនអោយបង្កើតរណសិរ្សរួបរួមជាតតិមួយប្រឆាំងវៀតណាម, តែខ្មែរក្រហមបដិសេធហើយនៅថ្ងៃទី ៨ ខែ កុម្ភះ ឆ្នាំ ១៩៨១ សម្តេចសីហនុ បានប្រកាសទិសដៅរួមគ្នារវាងគ្រប់កងកម្លាំងដែលប្រឆាំងនឹងរបបគ្រប់គ្រងនៅភ្នំពេញ ក៏នៅតែគ្មានលទ្ធិផលអ្វីដដែល ។ មកដល់ឆ្នាំ ១៩៨១ ថ្ងៃទី ២៦ ខែ មីនា ព្រះអង្គបានបង្កើតចលនា"ហ្វុនស៊ិនប៉ិច" ឡើងនៅប៉ារីសលើមូលដ្ឋានកងទ័ពតស៊ូម៉ូលីណាកា ។ ហើយនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៨២ ព្រះអង្គប្រកាសការព្យាយាមជាមួយហាណូយ ។ នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៨២ បក្សតស៊ូទាំងបីភាគីបានចុះហត្ថលេខា ព្រមព្រៀងគ្នាបង្កើតរដ្ឋាភិបាលត្រីភាគីនៅកូឡាឡាំពួរ ដោយម៉ូលីណាកា រដរបខនិងខ្មែរក្រហមឈ្មោះ"រដ្ឋាភិបាល ចម្រុះ កម្ពុជា ប្រជាធិបតេយ្យ" ។ ចាប់ពីឆ្នាំ ១៩៧៩ ត្រូវគេប៉ាន់ប្រមាណនៅកម្ពុជាមានបរិមាណសរុប១៥០០០០នាក់ ។ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៧៩ ក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ បានប្រកាសអោយកងទ័ពវៀតណាមចេញពីកម្ពុជាចាប់ពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៨២ ការចាកចេញកងទ័ពវៀតណាមនៅកម្ពុជាមានចំនួនតិចតួច ហើយការដកថយចេញពីកងទ័ពវៀតណាមមានលក្ខណះជាសន្សឹមៗពីមួយឆ្នាំទៅមួយឆ្នាំ ។ មកដល់ថ្ងៃទី ៥ ខែ មេសា ឆ្នា ១៩៨៩ សមមិត្តហ៊ុន សែនបានប្រកាសថា ដើម្បីផ្តល់ជាសម្បទានដ៏ចម្បងរបស់វៀតណាមនឹងដកកងទ័ព ,អ្នកជំនាញការនិងសាស្ត្រាចារ្យវៀតណាមទាំងអស់របស់ខ្លួនចេញពីប្រទេសកម្ពុជានៅចុងខែ កញ្ញា។

សរុបមកតាមរយះការសិក្សាស្រាវជ្រាវនៃរបបនេះ យើងឃើញថាការរីកចំរើននៅមានកំរិតស្មើគ្រប់វិស័យ ដូចជា សេដ្ឋកិច្ច កសិកម្ម ការអប់រំ នៅក្នុងរបបនេះ។ ដូច្នេះហើយសាធារណះរដ្ឋប្រជាមានិតកម្ពុជា មិនទទួលជំនួយអភិវឌ្ឍន៍ទេដោយហេតុថាខ្វះការទទួលស្គាល់ខាងការទូត ។ ក្នុងស្ថានភាពដ៏លំបាកនេះប្រជាជន ១០០ភាគរយជាអ្នកក្រីក្រ រចនាសម្ព័ជាតិខូចខាតទាំងស្រុង យើងគ្មានជម្រើសអ្វីក្រៅចងសម្ព័នមិត្តជាមួយប្រទេសវៀតណាម និងប្រទេសមួយចំនួនក្នុងប្លុកកុម្មុយនិស្ត ដូច្នេះសេដ្ឋកិច្ចរបស់ប្រទេស បានដើបឡើងវិញយ៉ាងយឺតៗ ។